**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**របាយការណ៍ស្រាវជ្រាវ**

# ការអភិវឌ្ឍបណ្ណាល័យ
# សាលារៀនចំណេះទូទៅនៅកម្ពុជា

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ហ៊ុន ឡាង**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ព្រុំ ទេវី**

ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច**
ឯកទេស**គ្រប់គ្រង** ជំនាន់១៦ ជំហាន២

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេររបាយការណ៍ ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**របាយការណ៍ស្រាវជ្រាវ**

# ការអភិវឌ្ឍបណ្ណាល័យ
# សាលារៀនចំណេះទូទៅនៅកម្ពុជា

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ហ៊ុន ឡាង**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ព្រុំ ទេវី**

ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច**
ឆ្នាំចូលសិក្សា ២០១៩

ឯកទេស**គ្រប់គ្រង** ជំនាន់១៦ ជំហាន២
ឆ្នាំសរសេររបាយការណ៍ ២០២០

# អារម្ភកថា

ការអប់រំ ត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្ស។ ធនធានមនុស្ស គឺជាកត្តាសំខាន់បំផុតសម្រាប់អភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន និងមានចីរភាព។ បច្ចុប្បន្នប្រទេសដែលរីកចម្រើននៅលើសកលលោក គឺជាប្រទេសដែលមានប្រព័ន្ធអប់រំប្រកបដោយគុណភាពខ្ពស់ និងធនធានមនុស្សគ្រប់គ្រាន់។ ការអប់រំ ត្រូវបានផ្តល់ជូនតាំងពីកុមារហូតដល់វ័យចំណាស់ តាមរយៈការសិក្សានៅកម្រិតមត្តេយ្យសិក្សា រហូតដល់ក្រោយឧត្តមសិក្សា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ឱ្យក្លាយជាពលរដ្ឋល្អ និងចេះរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរមនានៅក្នុងសង្គមជាតិ។

នៅព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅអប់រំប្រកបដោយចីរភាព ដែលជាមធ្យោបាយស័ក្តិសិទ្ធិក្នុងការធានាឱ្យការសិក្សាប្រកបដោយ គុណភាព បរិយាបន្ន និងសមធម៌ ព្រមទាំងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប។ ការសិក្សាពេញមួយជីវិត សំដៅលើការធានាសិទ្ធិ សេរីភាព និងសុភមង្គល បុគ្គល គ្រួសារ និងសង្គម ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ក្នុងបរិការណ៍នៃសាកលភាវូបនីយកម្ម ទាមទារឱ្យប្រទេសកម្ពុជា ដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការរបស់រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីអប់រំពាក់ព័ន្ធនានា ដើម្បីសម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាល ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។

ការអប់រំ នៅក្នុងសាលាគឺជារឿងសំខាន់ដែលមិនអាចខ្វះបាន ប៉ុន្តែមិនទាន់គ្រប់គ្រាន់នៅឡើយសម្រាប់ឆ្លើយតបទៅនឹងការអប់រំសម្រាប់ទាំងអស់គ្នា។ ការសិក្សារៀនសូត្រ អាចធ្វើឡើងបាននូវគ្រប់ទីកន្លែង ដោយមិនប្រកាន់ពេលវេលា ឬវ័យនោះឡើយ ប៉ុន្តែអ្វីដែលសំខាន់គឺធនធានឯកសារដែលត្រូវបានផ្តល់ជូនទៅអ្នកសិក្សារៀនសូត្រ ប្រកបដោយទំនុកចិត្ត និងគុណភាព។ បណ្ណាល័យ គឺជាកន្លែងមួយដែលផ្ទុកទៅដោយចំណេះដឹងមហាសាល ដែលមនុស្សគ្រប់រូបមិនគួរមើលរំលង និងត្រូវផ្តល់តម្លៃយ៉ាងជ្រាលជ្រៅ។ ថ្នាក់រៀនគ្រាន់តែជាកន្លែងផ្តល់ឱ្យយើងនូវចំណេះដឹងមួយផ្នែកតូច ប៉ុន្តែបណ្ណាល័យ គឺជាកន្លែងដែលផ្តល់នូវដំណោះស្រាយ បំណិន និងបទពិសោធន៍ ព្រមទាំងចំណេះដឹងយ៉ាងទូលំទូលាយ។ ការបណ្តុះទម្លាប់អាន គឺជាកត្តាសំខាន់សម្រាប់ឱ្យជំរុញឱ្យមានវប្បធម៌នៃការអាន គឺត្រូវផ្តល់ជូនកុមារតាំងពីកុមារភាព តាមរយៈបណ្ណាល័យសាលាបឋមសិក្សា រហូតដល់បណ្ណាល័យសាលាមធ្យមសិក្សា ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហ៊ុន ឡាវ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេស គ្រប់គ្រង ជំនាន់ទី១៦ ជំហាន២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សូមគោរពប្រណិប័តន៍ដោយសេចក្តីកតញ្ញូតាធម៌ចំពោះ**

លោកអ្នកមានគុណជា មាតា បិតា ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ និងឧបត្ថម្ភគ្រប់បែបយ៉ាង ទាំងផ្នែកស្មារតី សម្ភារៈ តាំងពីកុមារភាពរហូតដល់បានបញ្ចប់ថ្នាក់ក្រោយបរិញ្ញាបត្រ ដែលរូបលោកទាំងពីរបានជម្នះនូវរាល់ឧបសគ្គ ដោយមិនគិតពីការនឿយហត់គ្រប់បែបយ៉ាង។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការទទួលរាក់ទាក់ដ៏កក់ក្តៅជាទីបំផុតក្នុងការជួយឧបត្ថម្ភទាំងផ្នែកសម្ភារៈ និងស្មារតី ជាពិសេសការផ្ទេរចំណេះដឹងរបស់៖

- លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ទាំងអស់ដែលបានខិតខំបញ្ចេញទាំងកម្លាំងកាយចិត្តប្រាជ្ញាស្មារតី ក្នុងការផ្ទេរនូវពុទ្ធិ ឱវាទ ដែលប្រកបដោយគតិបណ្ឌិតដ៏ល្អជាច្រើនសម្រាប់ជាជំនួយស្មារតីដល់ខ្ញុំ។
- បណ្ឌិត ព្រុំ ទេវី ដែលជាសាស្ត្រាចារ្យណែនាំកិច្ចការស្រាវជ្រាវ ដើម្បីឱ្យខ្ញុំបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ថ្នាក់ក្រោយបរិញ្ញាបត្រប្រកបដោយជោគជ័យ។
- សូមថ្លែងអំណរគុណដល់ ថ្នាក់ដឹកនាំថ្នាក់កណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកផ្នែកស្ថិតិបណ្ណាល័យតាមមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលបានផ្តល់ឱកាសដល់ខ្ញុំបានចុះធ្វើការស្រាវជ្រាវព្រមទាំងផ្តល់នូវការសម្ភាស និងឯកសារពាក់ព័ន្ធនានាដើម្បីបង្កលក្ខណៈងាយស្រួលដល់ខ្ញុំក្នុងកំឡុងពេលស្រាវជ្រាវ។

ជាចុងក្រោយខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរមហាប្រសើរ កើតមានដល់ ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាយកថ្នាក់ក្រោយបរិញ្ញាបត្រ សាស្ត្រាចារ្យណែនាំ ថ្នាក់ដឹកនាំថ្នាក់កណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា មន្ត្រីទទួលបន្ទុកការងារបណ្ណាល័យមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ពិសេសមាតាបិតា សូមជួបប្រទះនូវសេចក្តីសុខចម្រើន និងសមប្រកបតាមសេចក្តីប្រាថ្នាព្រមទាំងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមគោរពអរគុណ**!

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## អំណះអំណាង

ខ្ញុំបាទឈ្មោះ **ហ៊ុន ឡាវ** កើតថ្ងៃទី១២ ខែមករា ឆ្នាំ១៩៨៩ នៅភូមិសាដំបង ឃុំដើមដូង ស្រុកអង្គរជ័យ ខេត្តកំពត។ បច្ចុប្បន្នជានិស្សិតថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រង (Master of Business in Managerment-MBM) ជំនាន់ទី១៦ ជំហាន២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៩-២០២០។

ខ្ញុំបាទសូមធានាអះអាងថា របាយការណ៍ស្រាវជ្រាវ ស្ដីពី **ការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា** គឺពិតជារបស់ខ្ញុំបាទ ដែលបានសិក្សាស្រាវជ្រាវដោយផ្ទាល់ និងមានទិន្នន័យដើមទាំងស្រុងពិតប្រាកដមែន។ របាយការណ៍ស្រាវជ្រាវនេះបានសរសេរឡើង ដោយមិនមានការលួចចម្លងពី របាយការណ៍ ឬនិក្ខេបបទ របស់អ្នកផ្សេងណាឡើយ។ ម្យ៉ាងវិញទៀត របាយការណ៍ស្រាវជ្រាវនេះពិតជាពុំទាន់បានប្រគល់ជូនទៅស្ថាប័ន ឬគ្រឹះស្ថានឧត្តមសិក្សាណាមួយ ដើម្បីទទួលបានសញ្ញាបត្រឡើយ។

ថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០២០

**ហ៊ុន ឡាវ**

# មាតិកា


អារម្ភកថា ........ i

សេចក្តីថ្លែងអំណរគុណ ........ ii

អំណះអំណាង ........ iii

មាតិកា ........ iv

បញ្ជីតារាង ........ vii

បញ្ជីរូប ........ viii

សេចក្តីផ្តើម ........ 1

១. លំនាំនៃការស្រាវជ្រាវ ........ 1

២. ចំណោទបញ្ហា ........ 2

៣. គោលបំណងនៃការស្រាវជ្រាវ ........ 2

៤. សំណួរស្រាវជ្រាវ ........ 3

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 3

៦. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ 3

៦.១. ទំហំ ........ 3

៦.២. ដែនកំណត់ ........ 3

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 4

៨. ការរៀបចំការស្រាវជ្រាវ ........ 4

៩. វិធីសាស្ត្រប្រមូលទិន្នន័យ ........ 5

៩.១. ទិន្នន័យចម្បង (Primary Data) ........ 5

៩.២. ទិន្នន័យបន្ទាប់បន្សំ (Secondary Data) ........ 5

១០. ប្រភេទនៃការសម្ភាសន៍ ........ 5

១១. ការវិភាគទិន្នន័យនៃការស្រាវជ្រាវ ........ 5

ជំពូកទី១ រំលឹកទ្រឹស្តី ........ 6

១.១. ប្រវត្តិកកើតបណ្ណាល័យនៅប្រទេសកម្ពុជា ........ 6

១.១.១. បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ........ 6

១.១.២. បណ្ណាល័យជាតិកម្ពុជា ........ 7

១.១.៣. បណ្ណសារដ្ឋានជាតិកម្ពុជា ........ 7

១.១.៤. បណ្ណាល័យផ្សេងៗ ........ 7

១.២. និយមន័យ ........ 8

១.៣. ប្រភេទបណ្ណាល័យ ........ 8

១.៤. តួនាទីបណ្ណាល័យ ........ 10

ជំពូកទី២ ទិដ្ឋភាពទូទៅនៃបណ្ណាល័យសាលារៀនចំណោះទូទៅនៅកម្ពុជា ........ 11

២.១. បណ្ណាល័យសាលាបឋមសិក្សា ........ 11

២.១.១. ស្ថានភាពបណ្ណាល័យ ........ 11

២.១.២. ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ ........ 14

២.១.៣. ការបំពាក់ធនធានឯកសារ ........ 14

២.១.៤. ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ ........ 14

២.២. បណ្ណាល័យអនុវិទ្យាល័យ ........ 16

២.២.១. ស្ថានភាពបណ្ណាល័យ ........ 16

២.២.២. ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ ........ 19

២.២.៣. ការបំពាក់ធនធានឯកសារ ........ 19

២.២.៤. ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ ........ 19

២.៣. បណ្ណាល័យវិទ្យាល័យ ........ 21

២.៣.១. ស្ថានភាពបណ្ណាល័យ ........ 21

២.៣.២. ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ ........ 24
២.៣.៣. ការបំពាក់ធនធានឯកសារ ........ 24
២.៣.៤. ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ ........ 24
ជំពូកទី៣ ការវិភាគលទ្ធផលនៃរបកគំហើញលើការអភិវឌ្ឍបណ្ណាល័យនៅកម្ពុជា ........ 26
៣.១. បញ្ហាប្រឈម ........ 26
៣.១.១. ធនធានមនុស្ស (បណ្ណារក្ស) ........ 26
៣.១.២. ធនធានឯកសារ ........ 26
៣.១.៣. ធនធានសម្ភារៈ និងបរិក្ខារ ........ 27
៣.១.៤. ថវិកាតាមសាលា ........ 27
៣.១.៥. ការគាំទ្របណ្ណាល័យ ........ 27
៣.១.៦. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យ ........ 27
៣.២. ដំណោះស្រាយ ........ 28
៣.២.១. ធនធានមនុស្ស (បណ្ណារក្ស) ........ 28
៣.២.២. ធនធានឯកសារ ........ 28
៣.២.៣. ធនធានសម្ភារៈ និងបរិក្ខារ ........ 28
៣.២.៤. ថវិកាតាមសាលា ........ 29
៣.២.៥. ការគាំទ្របណ្ណាល័យ ........ 29
៣.២.៦. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យ ........ 29
សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ 30
១. សេចក្តីសន្និដ្ឋាន ........ 30
២. អនុសាសន៍ ........ 31
គន្ថនិទ្ទេស ........ 32

# បញ្ជីតារាង

**ចំណងជើង** | **ទំព័រ**

១. តារាងទី១៖ ព័ត៌មានស្ថិតិបណ្ណាល័យសាលាបឋមសិក្សា ឆ្នាំ២០២០ ១២

២. តារាងទី២៖ ភាពខុសគ្នានៃការកំណត់ចំនួនបណ្ណារក្ស ១៥

៣. តារាងទី៣៖ ព័ត៌មានស្ថិតិបណ្ណាល័យអនុវិទ្យាល័យ ឆ្នាំ២០២០ ១៧

៤. តារាងទី៤៖ ព័ត៌មានស្ថិតិបណ្ណាល័យវិទ្យាល័យ ឆ្នាំ២០២០ ២២

# បញ្ជីរូប

**ចំណងជើង** **ទំព័រ**


១. រូបភាពទី១៖ ស្ថិតិបណ្ណាល័យសាលាបឋមសិក្សា ឆ្នាំ២០២០ ១៣

២. រូបភាពទី២៖ ស្ថិតិបណ្ណាល័យដំណើរការនៅសាលាបឋមសិក្សា ឆ្នាំ២០២០ ១៣

៣. រូបភាពទី៣៖ ស្ថិតិបណ្ណារក្សសាលាបឋមសិក្សា ឆ្នាំ២០២០ ១៥

៤. រូបភាពទី៤៖ ស្ថិតិបណ្ណាល័យអនុវិទ្យាល័យ ឆ្នាំ២០២០ ១៨

៥. រូបភាពទី៥៖ ស្ថិតិបណ្ណាល័យដំណើរការនៅអនុវិទ្យាល័យ ឆ្នាំ២០២០ ១៨

៦. រូបភាពទី៦៖ ស្ថិតិបណ្ណារក្សអនុវិទ្យាល័យ ឆ្នាំ២០២០ ២០

៧. រូបភាពទី៧៖ ស្ថិតិបណ្ណាល័យវិទ្យាល័យ ឆ្នាំ២០២០ ២៣

៨. រូបភាពទី៨៖ ស្ថិតិបណ្ណាល័យដំណើរការនៅវិទ្យាល័យ ឆ្នាំ២០២០ ២៣

៩. រូបភាពទី៩៖ ស្ថិតិបណ្ណារក្សវិទ្យាល័យ ឆ្នាំ២០២០ ២៥

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា កំពុងយកចិត្តយ៉ាងខ្លាំងក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា ឱ្យស្របតាមគោលនយោបាយនានារបស់រាជរដ្ឋាភិបាលអណត្តិទី៥។ ក្រសួងបានដាក់ចេញកំណែទម្រង់អប់រំជាច្រើនដោយឈរលើមូលដ្ឋានសសរស្តម្ភ៥គឺ ១. ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ២.ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា ៣. ការដាក់ឱ្យអនុវត្តអធិការកិច្ច ៤. ការពង្រឹងរង្វាយតម្លៃសិក្សាដូចជាការប្រឡង រង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ៥. ការកែទម្រង់ឧត្តមសិក្សា។ ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាចាំបាច់បំផុតសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ព្រោះធនធានមនុស្សជាកម្លាំងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ដោយឡែកសាលារៀនចំណេះទូទៅ គឺជាស្ថាប័នដ៏សំខាន់បំផុតក្នុងការផ្តល់សេវាអប់រំតាំងពីវ័យកុមារភាពរហូតដល់វ័យជំទង់ ចាប់ពីមត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សាទុតិយភូមិ។ សាលារៀននីមួយៗចាំបាច់ត្រូវមានបរិស្ថានសិក្សាល្អ ព្រមទាំងជាទីមេត្រីរបស់សិស្សានុសិស្សគ្រប់កម្រិត ក្នុងនោះបណ្ណាល័យសាលារៀនក៏ជាផ្នែកមួយដ៏សំខាន់ ក្នុងការជំរុញដល់ការអភិវឌ្ឍសមត្ថភាពរបស់សិស្សានុសិស្ស តាមរយៈការអាន ការស្រាវជ្រាវ និងកម្សាន្តផងដែរ។ បណ្ណាល័យមិនមែនត្រឹមជាឃ្លាំងផ្ទុកឯកសារទេ ប៉ុន្តែបណ្ណាល័យជាឃ្លាំងដែលផ្ទុកទៅដោយចំណេះដឹងមហាសាល តាមរយៈឯកសារដ៏សម្បូរបែបដោយការបម្រើសេវាកម្មប្រកបដោយទំនុកចិត្តថែមទៀត។ សម្រាប់ប្រទេសកម្ពុជា បណ្ណាល័យសាលារៀនចំណេះទូទៅហាក់ដូចជាពុំសូវរីកចម្រើន និងឆ្លើយតបទៅនឹងបរិបទនៃសង្គមបច្ចុប្បន្ន ដោយសារបណ្ណាល័យសាលារៀនចំណេះទូទៅភាគច្រើនពុំមានដំណើរការល្អ និងនិរន្តរភាពបានយូរអង្វែង។

ដោយមើលឃើញពីសារៈសំខាន់នៃបណ្ណាល័យសាលារៀនចំណេះទូទៅ ក្នុងការអភិវឌ្ឍធនធានមនុស្ស ទើបអ្នកស្រាវជ្រាវលើកយកប្រធានបទ **ការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា** ជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវ ដើម្បីជាគំនិត និងដំណោះស្រាយ សម្រាប់ជាជំនួយដល់អ្នកពាក់ព័ន្ធនានាក្នុងវិស័យនេះអ្នកធ្វើយ៉ាងណាឱ្យការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើន និងមាននិរន្តរភាព។

## ២. ចំណោទបញ្ហា

ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ក្នុងការកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា តាមរយៈដាក់ចេញនៅគោលនយោបាយសំខាន់ៗជាច្រើន ដើម្បីលើកកម្ពស់ដល់ការអប់រំឱ្យមានការរីកចម្រើន និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន។ ក្រសួងបានបង្កើតឱ្យមាន "ទិវាជាតិអំណាន" ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១១ ខែមីនា ជារៀងរាល់ឆ្នាំ ក្នុងគោលបំណងពង្រឹងឡើងវិញនូវវប្បធម៌អាន ជំរុញការអាន បណ្តុះទម្លាប់អាន ដើម្បីលើកកម្ពស់អក្សរសាស្ត្រក៏ដូចជាការអភិវឌ្ឍសមត្ថភាពរបស់ប្រជាពលរដ្ឋ។ សិស្សានុសិស្សមួយចំនួនបានពុំសូវយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ដោយសារខ្វះទម្លាប់នៃការអាន និងការស្រាវជ្រាវតាំងពីកុមារភាព ដែលជាហេតុធ្វើឱ្យសិស្សពុំសូវស្រឡាញ់ការអាន និងអត្រាបោះបង់ការសិក្សាខ្ពស់។ ការអានមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍសមត្ថភាពរបស់មនុស្ស ព្រោះចំណេះដឹងគ្រប់យ៉ាងរបស់មនុស្សមានប្រភពចេញពីការអាន និងការស្រាវជ្រាវ ដែលប្រភពសំខាន់គឺបណ្ណាល័យ។ ធ្វើយ៉ាងណាដើម្បីឱ្យការអភិវឌ្ឍបណ្ណាល័យនៅតាមសាលារៀនចំណេះទូទៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើន និងនិរន្តរភាព។

ផ្តោតចេញពីហេតុនេះហើយទើបធ្វើឱ្យអ្នកស្រាវជ្រាវផ្តោតសំខាន់ទៅលើ ការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសារតែបណ្ណាល័យសាលារៀន គឺជាផ្នែកមួយដ៏សំខាន់ក្នុងការជំរុញលើកកម្ពស់ចំណេះដឹងរបស់សិស្សានុសិស្ស តាមរយៈការផ្តល់នូវឯកសារគ្រប់យ៉ាងស្របតាមកម្មវិធីសិក្សា និងឯកសារផ្សេងៗទៀតសម្រាប់ជួយបង្កើនសតិបញ្ញា និងចំណេះដឹងរបស់សិស្ស។

គោលបំណងក្នុងការសិក្សាស្រាវជ្រាវនេះគឺ ធ្វើយ៉ាងណាដើម្បីអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា ឱ្យមានការរីកចម្រើន និងនិរន្តរភាព តាមរយៈការផ្តល់ឱកាសដល់សិស្សានុសិស្ស បណ្តុះទន្លាប់អាន និងលើកកម្ពស់សមត្ថភាពអាន។

## ៤. សំណួរស្រាវជ្រាវ

ដោយផ្អែកលើគោលបំណងខាងលើ យើងអាចចោទជាសំណួរមួយចំនួនដូចខាងក្រោម៖

១.តើការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជាមានស្ថានភាពបែបណានាពេលបច្ចុប្បន្ន?

២. តើមានបញ្ហា និងដំណោះស្រាយអ្វីខ្លះ ក្នុងការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា?

៣.តើកត្តាអ្វីខ្លះ ដែលជំរុញឱ្យបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា មានភាពរីកចម្រើន និងនិរន្តរភាព?

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវនេះនឹងរួមចំណែកក្នុងការផ្តល់ព័ត៌មានដល់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជានាយកដ្ឋានជំនាញពាក់ព័ន្ធនានា រៀបចំផែនការបែបណា ដើម្បីឱ្យបណ្ណាល័យសាលារៀនចំណេះទូទៅមានការអភិវឌ្ឍ និងមាននិរន្តរភាព ក្នុងការចូលរួមអភិវឌ្ឍធនធានមនុស្សក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះក៏ជាមូលដ្ឋានសម្រាប់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត តាមរយៈការវិភាគបែបវិទ្យាសាស្ត្រសង្គម។ ម្យ៉ាងទៀតក៏បានបង្ហាញពីបញ្ហាប្រឈម និងដំណោះស្រាយមួយចំនួន ដើម្បីជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហានៅតាមបណ្ណាល័យសាលារៀនចំណេះទូទៅឱ្យកាន់តែល្អប្រសើរផងដែរ។

## ៦. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៦.១. ទំហំ

ដោយសារបញ្ហាប្រឈមនេះ កើតឡើងទូទាំងប្រទេសកម្ពុជា ដូច្នេះដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះវិភាគបានគ្រប់ជ្រុងជ្រោយអ្នកស្រាវជ្រាវបានកំណត់យកទិន្នន័យបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា នៅកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ទូទាំង២៥ រាជធានី ខេត្ត។

### ៦.២. ដែនកំណត់

សម្រាប់ដែនកំណត់វិញ អ្នកស្រាវជ្រាវបានជ្រើសរើសទិន្នន័យសាលារៀនចំណេះទូទៅនៅកម្ពុជា ក្នុងឆ្នាំសិក្សា ២០១៩-២០២០ តាមរយៈមន្ត្រីទទួលបន្ទុកការងារបណ្ណាល័យនៃមន្ទីរអប់រំ យុវជន និងកីឡា មន្ត្រីថ្នាក់កណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

កិច្ចការសិក្សាស្រាវជ្រាវ ចែកចេញជា៥ចំណុចធំៗ គឺ

- សេចក្តីផ្តើម នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ និងវិធីសាស្ត្រវិភាគទិន្នន័យ។
- ជំពូកទី១ រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះ ដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី។
- ជំពូកទី២ ទិដ្ឋភាពទូទៅនៃបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញឃើញនូវស្ថានភាពបច្ចុប្បន្ននៃបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា។
- ជំពូកទី៣ ការវិភាគលទ្ធផលនៃរបកគំហើញលើការអភិវឌ្ឍបណ្ណាល័យនៅកម្ពុជា នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អនៅក្នុងស្ថានភាពជាក់ស្តែង។
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍ វាជាផ្នែកមួយដែលអ្នកស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងផ្តល់អនុសាសន៍មួយចំនួនក្នុងបំណងចូលរួមចំណែកធ្វើឱ្យការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង។

## ៨. ការរៀបចំការស្រាវជ្រាវ

ដើម្បីធ្វើការស្រាវជ្រាវលើប្រធានបទស្តីពី ការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា តម្រូវឱ្យមានការសិក្សាផ្ទាល់តាមវិធីសាស្ត្រជាក់ស្តែង និងច្បាស់លាស់ដើម្បីធ្វើការបកស្រាយ។ ដើម្បីទទួលបានទិន្នន័យទាំងយកមកវិភាគ យើងបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដូចជា៖ ជ្រើសរើសទីតាំងដើម្បីចុះស្រាវជ្រាវ ជ្រើសរើសប្រធានបទ កំណត់គោលបំណងនៃការស្រាវជ្រាវ ទំនាក់ទំនងទៅអង្គភាពពាក់ព័ន្ធដែលត្រូវចុះធ្វើការស្រាវជ្រាវ និងផ្តល់ជូននូវកម្រងសំណួរ និងធ្វើបទសម្ភាសន៍។

## ៩. វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យយើងបានប្រើប្រាស់នូវវិធីសាស្ត្រ២យ៉ាងគឺ

### ៩.១. ទិន្នន័យចម្បង ( Primary Data)

- ការចុះសាកសួរផ្ទាល់មាត់ជាមួយអ្នកដែលពាក់ព័ន្ធក្នុងប្រធានបទដូចជា ថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកការងារបណ្ណាល័យថ្នាក់កណ្តាល និងដៃគូអភិវឌ្ឍន៍

- ធ្វើការពន្យល់ និងផ្ញើទម្រង់ប្រមូលទិន្នន័យ ជូន ថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុការងារបណ្ណាល័យ មន្ទីរអប់រំ យុវជន និងកីឡាតាមរាជធានី ខេត្ត។

### ៩.២. ទិន្នន័យបន្ទាប់បន្សំ ( Secondary Data)

- ប្រមូលព័ត៌មានដែលទាក់ទងនឹងខ្លឹមសារប្រធានបទពីក្រសួងអប់រំ យុវជន និងកីឡា
- ឯកសារដែលផ្តល់ដោយមន្ទីរអប់រំ យុវជន និងកីឡា
- ឯកសារផ្សេងៗដែលមាននៅក្នុងបណ្ណាល័យ។

## ១០. ប្រភេទនៃការសម្ភាសន៍

យើងបានទៅជួបជាមួយអ្នកពាក់ព័ន្ធផ្នែកបណ្ណាល័យ ដែលបម្រើការនៅក្រសួងអប់រំ យុវជន និងកីឡា អង្គការ ដៃគូអភិវឌ្ឍន៍ និងអ្នកទទួលបន្ទុកការងារបណ្ណាលយនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដោយបានរៀបចំកម្រងសំណួរត្រឹមត្រូវ ហើយមានអត្ថន័យគ្រប់គ្រាន់សម្រាប់ពិពណ៌នានៅក្នុងជំពូកទី២។

## ១១. ការវិភាគទិន្នន័យនៃការស្រាវជ្រាវ

យើងបានយកទិន្នន័យដែលប្រមូលបានពី២៥ រាជធានី ខេត្ត និងកម្រងសំណួរដែលបានបំពេញដោយអ្នកពាក់ព័ន្ធបម្រើការនៅក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងដៃគូអភិវឌ្ឍន៍នានា យកមកវិភាគលើស្ថានភាពជាក់ស្តែងនៃបណ្ណាល័យតាមសាលារៀន ដោយសង្កត់ធ្ងន់ទៅលើបញ្ហាប្រឈម ដំណោះស្រាយ ព្រមទាំងវិធីសាស្ត្រដោះស្រាយផងដែរ។

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. ប្រវត្តិកកើតបណ្ណាល័យនៅប្រទេសកម្ពុជា

### ១.១.១. បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

កាលជំនាន់ដើម បុព្វបុរសខ្មែរយើងមានប្រពៃណីកត់ត្រាទុករឿងរ៉ាវ ព្រឹត្តិការណ៍ផ្សេងៗ និងក្បួនច្បាប់ទាំងឡាយនៅលើស្លឹករឹត នៅលើក្រាំង និងសិលាចារិក។ ចាប់ពីពេលដែលខ្មែរកាន់ព្រះពុទ្ធសាសនាមក យើងមានប្រពៃណីយកគម្ពីរ និងក្បួនច្បាប់ផ្សេងៗទៅថែរក្សាទុកក្នុងវត្តអារាមព្រោះវត្តគឺ ជាមណ្ឌលវប្បធម៌ សាលារៀន កន្លែងអប់រំបណ្តុះបណ្តាល និងជាជង្រុកនៃចំណេះដឹងផង។ ក្នុងវត្តអារាម មានកន្លែងមួយហៅថា ហោត្រ័យ (ហោត្រៃ) ដែលជាកន្លែងសម្រាប់តម្កល់គម្ពីរ និងក្បួនច្បាប់ទាំងអស់នោះ ជាពិសេសគឺគម្ពីរព្រះត្រៃបិដក។ នៅឆ្នាំ១៩២១ ក្នុងរជ្ជកាលព្រះករុណាព្រះបាទស៊ីសុវត្ថិ ព្រះអង្គបានបង្កើតបណ្ណាល័យមួយនៅភ្នំពេញដោយឱ្យឈ្មោះថា **ខេមរៈបណ្ណាល័យ**។ ក្រោយមកនៅឆ្នាំ១៩២៥ ខេមរៈបណ្ណាល័យ បានប្តូរឈ្មោះមកជា **ព្រះរាជបណ្ណាល័យ**។ ក្នុងសម័យនោះ ព្រះរាជបណ្ណាល័យ គឺជាជង្រុកឯកសារវប្បធម៌នៃប្រទេសកម្ពុជា ដែលឯកសារទាំងនោះបានប្រមូលនៅតាមវត្តអារាមនានាយកមកចម្លងដើម្បីរក្សាទុកជាឯកសារ។ កន្លងមកដល់ឆ្នាំ១៩៣០ ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស ព្រះអង្គបានស្ថាបនាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ហើយបញ្ចូលព្រះរាជបណ្ណាល័យក្នុងស្ថាប័ននេះដែរ។ ចាប់ពីពេលនោះមក ព្រះរាជបណ្ណាល័យ ក៏បានក្លាយមកជាបណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលមានសៀវភៅប្រមាណ៤០០០០ ក្បាល នៅមុនឆ្នាំ១៩៧៥។ ចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ បណ្ណាល័យនេះត្រូវបិទទ្វារ រីឯធនធានឯកសារទាំងមូល ក៏ត្រូវបំផ្លាញគ្មានសេសសល់។ នៅឆ្នាំ១៩៩២ បណ្ណាល័យនេះត្រូវបានបង្កើតឡើងវិញដោយស្ថិតក្រោមឱវាទរបស់ក្រសួងធម្មការ និងសម្តេចដាក់ឱ្យប្រើប្រាស់ក្រោយជួសជុលរួចក្រោមជំនួយរបស់អង្គការមនុស្សធម៌អាឡឺម៉ង់ឈ្មោះ ហេនរិចបូល នៅឆ្នាំ១៩៩៦ ។ នៅឆ្នាំ២០០២ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យប្តូរទីកន្លែងថ្មីក្រោមជំនួយរបស់អង្គការជប៉ុនឈ្មោះ វីស្សូ កូសីកៃ បណ្ណាល័យត្រូវបានប្តូរមកជាន់ក្រោមនៃវិទ្យាស្ថានវិញ។ បច្ចុប្បន្ន បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យមានសាខាចំនួន១៨ នៅតាមរាជធានី ខេត្ត ដែលមានទីតាំងនៅក្នុងមន្ទីរធម្មការខេត្ត និងក្នុងបរិវេណវត្តអារាម[1]។

[1] អាំង ជូបូះ ណែនាំការងារបណ្ណារក្ស, ភ្នំពេញ ឆ្នាំ២០០៦ ទំព័រទី៣។

### ១.១.២. បណ្ណាល័យជាតិកម្ពុជា

បណ្ណាល័យជាតិកម្ពុជា ត្រូវបានបង្កើត និងបើកទ្វារជូនសាធារណជនប្រើប្រាស់ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩២៤ ដោយរដ្ឋាភិបាលអាណានិគមបារាំងនៅឥណ្ឌូចិន ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ដោយប្រសិទ្ធនាមថា «បណ្ណាល័យកណ្តាល»។ រចនាសម្ព័ន្ធការងារក្នុងបណ្ណាល័យ បានបែងចែកជាផ្នែកសំខាន់ៗដូចជា ផ្នែកលេខាធិការដ្ឋាន ផ្នែកសាលអាន ផ្នែកសាលខ្ចីសៀវភៅ និងផ្នែកបណ្ណសារដ្ឋាន។ បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យនៅឆ្នាំ១៩៥៣ បារាំងបានផ្ទេរបណ្ណាល័យកណ្តាល មកឱ្យខ្មែរកាន់កាប់ជាសម្បត្តិជាតិយើងវិញ។ ចាប់ពីពេលនោះមក បណ្ណាល័យកណ្តាលត្រូវបានប្តូរឈ្មោះមកជា **បណ្ណាល័យជាតិ** វិញ។ បណ្ណាល័យជាតិបានបិទទ្វារនៅឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ នៅឆ្នាំ១៩៨០ បណ្ណាល័យជាតិបានបើកទ្វារសារជាថ្មី ដោយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ[2]។

### ១.១.៣. បណ្ណសារដ្ឋានជាតិកម្ពុជា

បណ្ណសារដ្ឋានជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩២៦ ក្នុងសម័យអាណានិគមបារាំង និងស្ថិតក្រោមការគ្រប់គ្រងរបស់ទេសាភិបាលបារាំងនៅកម្ពុជា។ បណ្ណសារដ្ឋានជាតិ ត្រូវបានផ្ទេរមកជាមរតកជាតិយើងវិញបន្ទាប់ពីបានទទួលឯករាជ្យនៅឆ្នាំ១៩៥៣ និងត្រូវបានបិទទ្វារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយឆ្នាំ១៩៧៩ បណ្ណសារដ្ឋានជាតិត្រូវបានរៀបចំឡើងវិញ និងស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ បណ្ណសារដ្ឋានជាតិ គឺជាកន្លែងតម្កល់ទុក ថែរក្សា នូវឯកសារដែលមានតម្លៃជាប្រវត្តិសាស្ត្រ ដែលត្រូវបានរដ្ឋបាលរបស់ប្រទេសបង្កើតឡើងក្នុងគោលបំណងបម្រើឱ្យការស្រាវជ្រាវរបស់ភ្ញៀវជាតិ និងអន្តរជាតិ[3]។

### ១.១.៤. បណ្ណាល័យផ្សេងៗ

ក្រោយពីប្រទេសកម្ពុជាទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ វិស័យសិក្សាធិការជាតិត្រូវបានរដ្ឋគិតគូរនិងយកចិត្តទុកដាក់។ គ្រឹះស្ថានសិក្សាគ្រប់កម្រិត ចាប់ពីសាលាបឋមសិក្សាដល់សាកលវិទ្យាល័យត្រូវបានកសាងបណ្តើរៗនៅគ្រប់ទិសទីក្នុងប្រទេស។ គ្រឹះស្ថានសិក្សានីមួយតែងមានបណ្ណាល័យនៅជាប់ជាមួយ ដើម្បីបម្រើឱ្យ

[2] អាំង ជូលាន-ដ.ឯ.ម- ទំព័រទី៨។

[3] -ដ- ទំព័រទី១១។

ការស្រាវជ្រាវរបស់សិស្ស-និស្សិត។ ចំណែកនៅតាមក្រសួងនិងស្ថាប័ននានារបស់រដ្ឋវិញ ក៏មានកន្លែងតម្កល់ឯកសារ សៀវភៅផ្សេងៗ ដែលខ្លះហៅថាបណ្ណាល័យ និងខ្លះទៀតហៅថា មជ្ឈមណ្ឌលឯកសារ។

ក្នុងទសវត្សឆ្នាំ៩០ មានបណ្ណាល័យធំៗចំនួនពីរត្រូវបានបង្កើតឡើងគឺ បណ្ណាល័យមជ្ឈមណ្ឌលវប្បធម៌បារាំង និងបណ្ណាល័យ ហ៊ុន សែន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ[4] ។

## ១.២. និយមន័យ

បណ្ណាល័យ គឺជាកន្លែងសម្រាប់តម្កល់ឯកសារគ្រប់បែបយ៉ាង ដែលអ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រខិតខំសិក្សាស្រាវជ្រាវ ចងក្រង បន្សល់ទុកឱ្យអ្នកជំនាន់ក្រោយ ដើម្បីជាទុនក្នុងការសិក្សាស្រាវជ្រាវបង្កើនចំណេះដឹងសម្រាប់យកទៅអនុវត្តក្នុងជីវភាពរស់នៅរបស់ពួកគេ។

បណ្ណាល័យសាលារៀន គឺជាកន្លែងដែលផ្ទុកឯកសារគ្រប់យ៉ាងស្របតាមកម្មវិធីសិក្សា និងឯកសារចំណេះដឹងផ្សេងៗទៀតសម្រាប់បម្រើឱ្យការសិក្សារបស់សិស្ស ជាពិសេសជួយបង្កើនសតិបញ្ញា បណ្តុះទម្លាប់អាន និងចំណេះដឹងរបស់សិស្ស។ បណ្ណាល័យសាលារៀន គឺមាននៅតាមសាលាបឋមសិក្សា រហូតដល់វិទ្យាល័យ។

## ១.៣. ប្រភេទបណ្ណាល័យ

នៅប្រទេសកម្ពុជាមានបណ្ណាល័យជាច្រើនដូចជា៖

**បណ្ណាល័យជាតិ** គឺជាកន្លែងតម្កល់ទុកនូវ ស្មារតី របស់ប្រទេសមួយ ព្រោះបណ្ណាល័យជាតិមានតួនាទីជាអ្នកប្រមូលផ្តុំ និងថែរក្សាទុកជាបេតិកភណ្ឌជាតិ នូវការផលិត និងចេញផ្សាយគ្រប់ប្រភេទ ឯកសាររបស់ប្រទេសនោះ សម្រាប់ធ្វើជាគន្លងនិទ្ទេសជាតិ តាមរយៈច្បាប់តម្កល់ទុកតាមច្បាប់[5]។

**បណ្ណាល័យសាធារណៈ** គឺជាបណ្ណាល័យដែលមានធនធានឯកសារទាក់ទងនឹងគ្រប់ប្រធានបទ គ្រប់មុខវិជ្ជា ហើយគឺជាបណ្ណាល័យដែលមានបណ្តាញនៅគ្រប់ទិសទីក្នុងប្រទេស ព្រមទាំងជាបណ្ណាល័យដែលបើកទ្វារទទួលសាធារណៈជនទូទៅ ដោយពុំរើសមុខចាប់ពីកុមាររហូតដល់មនុស្សចាស់[6]។

[4] អាំង ជូលាន-ដ.ឯ.ម- ទំព័រទី១៥។

[5] -ដ- ទំព័រទី៤៩។

[6] -ដ- ទំព័រទី៤៩។

**បណ្ណាល័យសាកលវិទ្យាល័យ** គឺជាបណ្ណាល័យនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលមានតួនាទីផ្តល់ឱ្យនិស្សិត និងសាស្ត្រាចារ្យ នូវឯកសារគ្រប់ប្រភេទ ដែលចាំបាច់ក្នុងការសិក្សានិងការស្រាវជ្រាវ។

**បណ្ណាល័យឯកទេស** គឺជាបណ្ណាល័យដែលមានធនធានឯកសារទាក់ទងតែនឹងប្រធានបទពិសេសណាមួយ[7]។

**បណ្ណាល័យសាលារៀន** គឺជាបណ្ណាល័យនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា ហើយស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

បច្ចុប្បន្នយោងតាមភាពរីកចម្រើននៃបច្ចេកវិទ្យា ការគ្រប់គ្រងបណ្ណាល័យមានបីប្រភេទដូចខាងក្រោមៈ

**បណ្ណាល័យបុរាណ** គឺជាបណ្ណាល័យដែលមានលក្ខណៈជាអគារ ឬបន្ទប់ មានរៀបចំធ្នើរ ឬ ទូសម្រាប់ផ្ទុកសៀវភៅ ឬឯកសារ មានកន្លែងសម្រាប់អង្គុយអាន និងខ្ចីសង។ ការកត់ត្រា និងការចុះបញ្ជីផ្សេងៗ គឺសរសេរដោយដៃ។ ការស្វែងរកឯកសារ ឬសៀវភៅទាមទារការចំណាយពេលយូរ ដោយត្រូវទៅរកតាមធ្នើរឬទូនីមួយៗ[8]។

**បណ្ណាល័យបែបស្វ័យប្រវត្តិ** គឺជាបណ្ណាល័យដែលមានលក្ខណៈជាអគារ ឬបន្ទប់ មានរៀបចំធ្នើរ ឬ ទូសម្រាប់ផ្ទុក សៀវភៅ ឬឯកសារ មានកន្លែងសម្រាប់អង្គុយអាន និងខ្ចីសង ដូចជាបណ្ណាល័យបុរាណដែរ ប៉ុន្តែបណ្ណាល័យប្រភេទនេះ បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមកុំព្យូទ័រ សម្រាប់ការបញ្ចូលទិន្នន័យសៀវភៅមួយចំនួនដូចជា ចំណងជើងសៀវភៅ ឈ្មោះអ្នកនិពន្ធ គ្រឹះស្ថានបោះពុម្ព ឆ្នាំបោះពុម្ព ប្រភេទសៀវភៅ លេខកូដសៀវភៅ លេខISBN ពាក្យគន្លឹះ និងការសង្ខេបខ្លឹមសារសៀវភៅ។ ការកត់ត្រា និងការចុះបញ្ជីមួយចំនួនត្រូវបានប្រើប្រាស់ដោយកុំព្យូទ័រ ជាពិសេសអាចឱ្យអ្នកអានអាចស្វែងរកសៀវភៅនិងខ្ចីសងបានរហ័ស[9]។

**បណ្ណាល័យអេឡិកត្រូនិច** គឺជាមូលដ្ឋានទិន្នន័យ (Database) ដែលមានឯកសារសម្បូរបែបហើយទូលំទូលាយជាប្រភេទ E-Book សម្រាប់បម្រើដល់អ្នកអាន អ្នកស្រាវជ្រាវ មើល ឬអានបានពីចម្ងាយតាមរយៈប្រព័ន្ធអ៊ីនធើណែត។ បណ្ណាល័យប្រភេទនេះ គឺផ្តល់ភាពងាយស្រួលសម្រាប់អ្នកអាន និងអ្នកស្រាវជ្រាវ ក្នុងការស្វែងរកឯកសារ ដោយគ្រាន់តែបញ្ចូលពាក្យគន្លឹះ គេនឹងទទួលបានព័ត៌មានយ៉ាងឆាប់រហ័ស[10]។

---

[7] អាំង ជូបូះ-ដ.ឯ.ម- ទំព័រទី៤៩។

[8] ឃ្លោក វិបុលឡា និងអ្នកដទៃ៖ ឯកសារណែនាំការងារបណ្ណាល័យសាលាមធ្យមសិក្សា, ភ្នំពេញ ឆ្នាំ២០១០ ទំព័រទី៣។

[9] -ដ- ទំព័រទី៣។

[10] -ដ- ទំព័រទី៤។

## ១.៤. តួនាទីបណ្ណាល័យ

បណ្ណាល័យដើរតួនាទីមួយដ៏សំខាន់ ដោយត្រូវផ្តល់ឯកសារគ្រប់បែបយ៉ាងសម្រាប់ការរៀនសូត្រ ព្រមទាំងជួយអ្នកអានឱ្យចេះប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធានឯកសារទាំងនោះ។ ម្យ៉ាងទៀតភាពជោគជ័យនៃការរៀនសូត្រ គឺបានមកពីលទ្ធភាពទទួលបានព័ត៌មាន និងចេះប្រើប្រាស់ព័ត៌មានទាំងនោះ។ ការរៀនសូត្រ និងការបណ្តុះបណ្តាលខ្លួនរបស់មនុស្សយើងម្នាក់ៗចាប់ពីបឋមសិក្សាដល់សាកលវិទ្យាល័យ និងមនុស្សភាគច្រើនការសិក្សារៀនសូត្រ គឺជាសកម្មភាពអចិន្ត្រៃយ៍ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនទៅតាមបរិបទសង្គម និងការរីកចម្រើនរបស់សង្គម។

បណ្ណាល័យសាលារៀនមានតួនាទី ផ្តល់សៀវភៅ និងឯកសារផ្សេងៗសម្រាប់បម្រើការរៀនសូត្ររបស់កុមារ ទៅតាមកម្រិតអាយុ និងតាមកម្មវិធីសិក្សារបស់សាលា ដោយមានបន្ថែមឯកសារផ្សេងៗទៀតសម្រាប់ជួយបណ្តុះបណ្តាលប្រាជ្ញាស្មារតីរបស់កុមារ និងសិស្ស តាំងពីសាលាបឋមសិក្សា រហូតដល់មធ្យមសិក្សា។

បណ្ណាល័យមានតួនាទីសំខាន់ៗផ្សេងទៀតដូចជា៖

**ប្រមូលផ្តុំឯកសារ** គឺប្រមូលផ្តុំឯកសារគ្រប់ប្រភេទ និងគ្រប់ប្រធានបទឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន ដើម្បីបង្កលក្ខណៈងាយស្រួល និងបម្រើឱ្យអ្នកអានគ្រប់កម្រិត ទាំងជាតិ និងអន្តរជាតិ សិស្ស និស្សិត សាស្ត្រាចារ្យ មន្ត្រីរាជការ ប្រជាពលរដ្ឋ ព្រះសង្ឃ បានចូលអាន និងសិក្សាស្រាវជ្រាវ។

**ថែរក្សាមរតកវប្បធម៌ជាតិ និងអន្តរជាតិ** គឺបណ្ណាល័យមានតួនាទីថែរក្សា ការពារឯកសារគ្រប់ប្រភេទ ដើម្បីចៀសវាងការខូចខាតដោយកត្តា ធម្មជាតិ សត្វ និងមនុស្សបំផ្លាញ។ តួនាទីនេះធ្វើឱ្យឯកសារគង់វង្សយូរអង្វែង សម្រាប់ជាមរតកសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។

**ផ្សព្វផ្សាយព័ត៌មាន** បណ្ណាល័យគឺជាមជ្ឈមណ្ឌលព័ត៌មានដែលសាធារណជន អាចរកបានដោយងាយស្រួលនូវព័ត៌មានគ្រប់បែបយ៉ាងព្រមទាំងចំណេះដឹងទាំងឡាយ។ ម្យ៉ាងទៀត បណ្ណាល័យត្រូវផ្សព្វផ្សាយព័ត៌មានតាមរយៈសេចក្តីជូនដំណឹង និងបើទ្វារបម្រើដល់អ្នកអាន អ្នកស្រាវជ្រាវ តាមសេចក្តីត្រូវការមកពីគ្រប់មជ្ឈដ្ឋាន[11]។

[11] អ៊ឹម ម៉ាចះ កិច្ចការបណ្ណាល័យសម្រាប់សាលាបឋមនិងមធ្យមសិក្សា, ភ្នំពេញ ឆ្នាំ២០១៣ ទំព័រទី៤៧។

# ជំពូកទី២

# ទិដ្ឋភាពទូទៅនៃបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា

## ២.១. បណ្ណាល័យសាលាបឋមសិក្សា

### ២.១.១. ស្ថានភាពបណ្ណាល័យ

បច្ចុប្បន្ននៅកម្ពុជា សាលាបឋមសិក្សាសាធារណៈ (រដ្ឋ) សរុបចំនួន ៧,២៨៣ ក្នុងនោះសាលាដែលមានបណ្ណាល័យសរុបចំនួន៤,៤៨៨ សាលា ស្មើនឹង ៦២ភាគរយ ហើយបណ្ណាល័យដែលដំណើរការមានចំនួន ៣,៦១០ ស្មើនឹង ៨០ភាគរយ នៃចំនួនបណ្ណាល័យសរុបទាំងអស់។ បណ្ណាល័យភាគច្រើនមានលក្ខណៈជា អគារ បន្ទប់ ក្នុងទីចាត់ការ និងមួយចំនួនតូចមានលក្ខណៈជា ជ្រុងថ្នាក់ និងចល័ត។ បណ្ណាល័យដែលមានដំណើរការភាគច្រើនជាបណ្ណាល័យដែលមានលក្ខណៈជា អគារ និងបន្ទប់ ចំពោះបណ្ណាល័យ ក្នុងទីចាត់ការ ជ្រុងថ្នាក់ និងចល័ត ពុំសូវមានដំណើរការទេ ដោយសារខ្វះខាតធនធានសម្ភារៈ បរិក្ខារ និងធនធានឯកសារ ព្រមទាំងគ្មានអ្នកគ្រប់គ្រងច្បាស់លាស់។ ក្នុងចំណោមបណ្ណាល័យដែលដំណើរការចំនួន ៣,៦១០ នោះក៏មានបណ្ណាល័យដំណើរការមិនពេញលេញផងដែរ ព្រោះសាលារៀនដែលដំណើរការពីរពេល (២វេន) ប៉ុន្តែបណ្ណាល័យដំណើរការតែមួយពេល (១វេន) ដោយសារខ្វះបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ។ ការគ្រប់គ្រងឯកសារ និងកត់ត្រាភាគច្រើនប្រើប្រាស់ដោយដៃតាមលក្ខណៈប្រពៃណីនូវឡើយ ប៉ុន្តែក៏មានបណ្ណាល័យមួយចំនួនតូចដែលមានការប្រើប្រាស់កុំព្យូទ័រខ្លះសម្រាប់គ្រប់គ្រងបញ្ជីសៀវភៅផ្សេងៗ ដែលបណ្ណាល័យទាំងនោះបានទទួលការឧបត្ថម្ភពីអង្គការ ដៃគូអភិវឌ្ឍន៍ និងសប្បុរសជននានា។ សព្វថ្ងៃមានអង្គការមួយចំនួនដែលបានចូលរួមអភិវឌ្ឍបណ្ណាល័យបឋមសិក្សា ដូចជា អង្គការរូមធូរីដ (Room To Read), អង្គការស៊ីប៉ា (Sipar), អង្គការសង្គ្រោះកុមារកម្ពុជា (Save the Children), អង្គការខេប (KAPE), អង្គការសន្តិស្ម័គ្រចិត្ត (SVA), អង្គការភ្លែនអន្តរជាតិកម្ពុជា (Plan international Cambodia), អង្គការឆាល់ហ្វាន់ (Child Fund Cambodia), អង្គការមូលនិធិអាស៊ី (The Asian Foundation), អង្គការ World vision international, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ និងអង្គការផ្សេងៗទៀត។ ក្នុងនោះការចូលរួមអភិវឌ្ឍទៅលើ អគារ សម្ភារៈ បរិក្ខារ ធនធានឯកសារ និងការបណ្តុះបណ្តាលបច្ចេកទេសជាដើម។ ទោះបីជាមានដៃគូអភិវឌ្ឍន៍ និងអង្គការ ជាមួយចំនួនបានចូលរួមអភិវឌ្ឍបណ្ណាល័យសាលារៀនក៏ដោយ ក៏នៅមានចំនួនតិចតួចនៅឡើយបើប្រៀបធៀបទៅនឹងចំនួនសាលារៀនបឋមសិក្សា។ បណ្ណាល័យខ្លះបន្ទាប់ពីបញ្ចប់គម្រោង បានបិទទ្វារ ឬមិនសូវមានដំណើរការ ដោយសារ ខ្វះខាតធនធានឯកសារថ្មីៗសម្រាប់ទាក់ទាញកុមារឱ្យចូលរប្រើប្រាស់។

## តារាងទី១៖ ព័ត៌មានស្ថិតិបណ្ណាល័យសាលាបឋមសិក្សា ឆ្នាំ២០២០

| ព័ត៌មានស្ថិតិបណ្ណាល័យសាលាបឋមសិក្សាឆ្នាំ ២០២០ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | រាជធានី/ខេត្ត | បរិយាយ | | | | |
| | | ចំនួនសាលា | ចំនួនបណ្ណាល័យ | ដំណើរការ | ចំនួនបណ្ណារក្ស | ធ្លាប់បំប៉ន |
| ១ | បន្ទាយមានជ័យ | 408 | 285 | 192 | 228 | 140 |
| ២ | បាត់ដំបង | 649 | 300 | 266 | 370 | 106 |
| ៣ | កំពង់ចាម | 408 | 322 | 297 | 356 | 160 |
| ៤ | កំពង់ឆ្នាំង | 281 | 157 | 156 | 159 | 82 |
| ៥ | កំពង់ស្ពឺ | 314 | 213 | 153 | 199 | 102 |
| ៦ | កំពង់ធំ | 490 | 268 | 227 | 178 | 106 |
| ៧ | កំពត | 311 | 234 | 234 | 153 | 69 |
| ៨ | កណ្តាល | 373 | 265 | 262 | 280 | 56 |
| ៩ | កែប | 22 | 22 | 18 | 18 | 10 |
| ១០ | កោះកុង | 121 | 56 | 34 | 40 | 20 |
| ១១ | ក្រចេះ | 286 | 107 | 84 | 91 | 68 |
| ១២ | មណ្ឌលគិរី | 88 | 36 | 29 | 30 | 2 |
| ១៣ | ឧត្តរមានជ័យ | 218 | 44 | 43 | 60 | 35 |
| ១៤ | ប៉ៃលិន | 48 | 19 | 17 | 21 | 6 |
| ១៥ | រាជធានីភ្នំពេញ | 164 | 152 | 108 | 118 | 38 |
| ១៦ | ព្រះសីហនុ | 72 | 51 | 44 | 57 | 22 |
| ១៧ | ព្រះវិហារ | 228 | 77 | 37 | 41 | 20 |
| ១៨ | ព្រៃវែង | 547 | 332 | 237 | 251 | 160 |
| ១៩ | ពោធិ៍សាត់ | 305 | 283 | 75 | 75 | 18 |
| ២០ | រតនគិរី | 222 | 65 | 65 | 68 | 23 |
| ២១ | សៀមរាប | 507 | 419 | 370 | 516 | 180 |
| ២២ | ស្ទឹងត្រែង | 173 | 53 | 47 | 54 | 26 |
| ២៣ | ស្វាយរៀង | 262 | 176 | 160 | 166 | 43 |
| ២៤ | តាកែវ | 382 | 368 | 310 | 311 | 253 |
| ២៥ | ត្បូងឃ្មុំ | 404 | 184 | 145 | 184 | 84 |
| **សរុប** | | 7283 | 4488 | 3610 | 4024 | 1829 |

**ប្រភព៖ អ្នកនិពន្ធ**

## រូបភាពទី១៖ ស្ថិតិបណ្ណាល័យសាលាបឋមសិក្សា ឆ្នាំ២០២០




ប្រភព៖ អ្នកនិពន្ធ

## រូបភាពទី២៖ ស្ថិតិបណ្ណាល័យដំណើរការនៅសាលាបឋមសិក្សា ឆ្នាំ២០២០




ប្រភព៖ អ្នកនិពន្ធ

### ២.១.២. ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ

តាមការសង្កេតឃើញថា ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ នៅតាមបណ្ណាល័យសាលាបឋមសិក្សានៅមានកម្រិតតិចតួច និងមិនទាន់សមស្របទៅតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។ ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារបណ្ណាល័យបឋមសិក្សា ត្រូវសមស្របទៅនឹងកម្រិតអាយុរបស់កុមារ និងផ្តល់ភាពងាយស្រួលដល់កុមារក្នុងការស្វែងរក ចាប់យកសៀវភៅមកអាន និងមិនមានហានិភ័យណាមួយចំពោះកុមារ។ ទោះបីជាធនធានសម្ភារៈ និងបរិក្ខារមួយចំនួនមិនស្របតាមការណែនាំក៏ដោយ ក៏បណ្ណាល័យបានដាក់ឱ្យប្រើប្រាស់ប្រសើរជាងមិនដំណើរការ ក្នុងនោះមានបណ្ណាល័យមានប្រហែល៤០ភាគរយ ដែលបានបំពាក់ធនធានសម្ភារៈ និងបរិក្ខារ អាចល្មមដំណើរការបាន ដោយឡែកចំពោះបណ្ណាល័យប្រមាណ៦០ភាគរយមានសម្ភារៈ និងបរិក្ខារតិចតួចនៅឡើយ។ ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ ភាគច្រើនបានទទួលការឧបត្ថម្ភពី អង្គការ ដៃគូអភិវឌ្ឍ សប្បុរសជន និងការប្រើប្រាស់ថវិកាជាតិ (PB)។

### ២.១.៣. ការបំពាក់ធនធានឯកសារ

ការបំពាក់ឯកសារក្នុងបណ្ណាល័យបឋមសិក្សា សង្កេតឃើញថាមានលក្ខណៈល្អបង្គួរ ដែលភាគច្រើនគឺជាសៀវភៅអក្សរសិល្ប៍ បានជំរុញឱ្យកុមារចូលប្រើប្រាស់ក្នុងបណ្ណាល័យ តាមរយៈការអាន ឬនិទានរឿង ដោយគ្រូបង្រៀន និងបណ្ណារក្ស។ សាលារៀនដែលមានបណ្ណាល័យ មានអត្រាកុមារចេះអក្សរខ្ពស់ជាងសាលាដែលគ្មានបណ្ណាល័យ ហើយចំនួនកុមារដែលមកសិក្សាក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ការបំពាក់ឯកសារនៅក្នុងបណ្ណាល័យបឋមសិក្សា ត្រូវធ្វើគិតទៅតាមកម្រិតអាយុរបស់កុមារ និងចំណេះដឹងរបស់កុមារដើម្បីឱ្យកុមារអាចជ្រើសរើសសៀវភៅទៅតាមកម្រិត ឬចំណេះដឹងរបស់ខ្លួន។ បណ្ណាល័យបឋមសិក្សាមួយចំនួនទទួលបានឯកសារពី សប្បុរសជន អង្គការ ដៃគូអភិវឌ្ឍន៍ សហគមន៍ និងមួយចំនួនទៀតបានពីការប្រើប្រាស់ថវិការបស់សាលាផងដែរ។ បណ្ណាល័យមួយចំនួនដែលមានការគាំទ្រដោយ សប្បុរជន អង្គការ ដៃគូអភិវឌ្ឍន៍ និងសហគមន៍ ដែលធ្វើឱ្យមានដំណើរការបានល្អ ដោយសារមានធនធានឯកសារគ្រប់គ្រាន់។

### ២.១.៤. ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ

ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យនៅតាមសាលារៀនភាគច្រើន គឺជាគ្រូបង្រៀនដែលមានសុខភាពទន់ខ្សោយ និងគ្រូដែលពុំសូវសកម្ម ព្រមទាំងពុំមានចំណេះដឹងផ្នែកគ្រប់គ្រងបណ្ណាល័យ ដែលជាហេតុធ្វើឱ្យបណ្ណាល័យភាគច្រើនពុំសូវមានដំណើរការល្អ។ បណ្ណារក្សប្រមាណពី ៤០ភាគរយ ទៅ ៥០ភាគរយ

មានវ័យចំណាស់ មានសុខភាពមិនសូវល្អ និងចំណេះដឹងកម្រិតទាប។ ការកំណត់ចំនួនបណ្ណារក្សតាមសាលានៅមិនទាន់មានការឯកភាពគ្នាទូទាំងប្រទេសនៅឡើយ ដោយខេត្តខ្លះប្រើប្រាស់តាមស្តង់ដាបណ្ណាល័យបឋមសិក្សា ដែលផ្សាយចេញពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បោះពុម្ពឆ្នាំ២០១១ និងខេត្តខ្លះអនុវត្តតាម សេចក្តីណែនាំលេខ២០ អយក.សណន ស្តីពីនិយាមប្រើបុគ្គលិកអប់រំ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨។ ម្យ៉ាងទៀតការផ្លាស់ប្តូរបណ្ណារក្សញឹកញាប់តាមសាលាធ្វើឱ្យបណ្ណាល័យបើកទ្វារមិនទៀតទាត់ផងដែរ។ បណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យសរុបចំនួន ៤,០២៤ នាក់ មានតែបណ្ណារក្សចំនួន ១,៨២៩ នាក់ ស្មើនឹង៤៥ភាគរយ ដែលទទួលបានការបំប៉នពីការងារបណ្ណាល័យ។

**តារាងទី២៖ ភាពខុសគ្នានៃការកំណត់ចំនួនបណ្ណារក្ស**

| ស្តង់ដាបណ្ណាល័យបឋមសិក្សា ឆ្នាំ២០១១ | | សេចក្តីណែនាំ លេខ ២០ អយក.សណន | |
|---|---|---|---|
| **ចំនួនថ្នាក់** | **ចំនួនបណ្ណារក្ស** | **ចំនួនថ្នាក់** | **ចំនួនបណ្ណារក្ស** |
| **១០ថ្នាក់ ចុះក្រោម** | ១ | ចាប់ពី ៦ថ្នាក់-២០ថ្នាក់ | ១ |
| **ចាប់ពី ១១ថ្នាក់-៤០ថ្នាក់** | ២ | ចាប់ពី ២១ថ្នាក់-៤០ថ្នាក់ | ២ |
| **ចាប់ពី ៤១ថ្នាក់ឡើងទៅ** | ៣ | ចាប់ពី ៤១ថ្នាក់ឡើងទៅ | ៣ |

**ប្រភព៖ ស្តង់ដារបណ្ណាល័យបឋមសិក្សា និងសេចក្តីណែនាំលេខ ២០**

**រូបភាពទី៣៖ ស្ថិតិបណ្ណារក្សសាលាបឋមសិក្សា ឆ្នាំ២០២០**




**ប្រភព៖ អ្នកនិពន្ធ**

## ២.២. បណ្ណាល័យអនុវិទ្យាល័យ

### ២.២.១. ស្ថានភាពបណ្ណាល័យ

អនុវិទ្យាល័យគឺជាកម្រិតទីពីរនៃប្រព័ន្ធអប់រំនៅកម្ពុជា នៅឆ្នាំ២០២០ សាលារៀនសរុបមានចំនួន១,២៤៨ សាលាដែលមានបណ្ណាល័យចំនួន ៧៦៨ ស្មើនឹង៦២ភាគរយ ហើយបណ្ណាល័យដែលដំណើរការមានចំនួន ៥៨៨ ស្មើនឹង ៧៧ ភាគរយ នៃចំនួនបណ្ណាល័យសរុប។ នៅកម្រិតអនុវិទ្យាល័យក៏មិនខុសពីបណ្ណាល័យសាលាបឋមសិក្សាប៉ុន្មានដែរ បណ្ណាល័យមានលក្ខណៈជា អគារ បន្ទប់ ក្នុងទីចាត់ការ និងមួយចំនួនទៀតមានលក្ខណៈជា ជ្រុងថ្នាក់ និងចល័ត។ សាលារៀនដែលគ្មានបណ្ណាល័យភាគច្រើន បណ្ដាលមកពីខ្វះបន្ទប់ និងជាសាលាដែលមិនគ្រប់កម្រិត។ សាលារៀនដែលមានបណ្ណាល័យ ប៉ុន្តែមិនមានដំណើរការភាគច្រើន ដោយសារពុំមានបណ្ណារក្ស ឬអ្នកគ្រប់គ្រងច្បាស់លាស់ និងការជ្រើសរើសគ្រូមកគ្រប់គ្រងមានការផ្លាស់ប្ដូរញឹកញាប់ ជាពិសេសគឺជ្រើសរើសបានតែគ្រូដែលមានបញ្ហាសុខភាពមិនសូវល្អ និងអសកម្មក្នុងការងារ។ ចំពោះការបើកដំណើរការបណ្ណាល័យក៏មានបញ្ហាដូចគ្នាទៅនឹងសាលាបឋមសិក្សាដែរ ព្រោះសាលារៀនដែលបើកដំណើរការបង្រៀនពីរពេល(២វេន) ប៉ុន្តែបណ្ណាល័យដំណើរការតែមួយពេល (១វេន) ដោយសារខ្វះបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ ម្យ៉ាងទៀតបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យភាគច្រើនត្រូវធ្វើការជាបណ្ណារក្សផង និងបង្រៀនផង ដោយសារខ្វះគ្រូ។ បញ្ហាមួយទៀតដែលកើតនៅកម្រិតអនុវិទ្យាល័យ គឺសាលារៀនដែលមិនគ្រប់កម្រិត ប៉ុន្តែមានបណ្ណាល័យ ហើយពុំមានបណ្ណារក្សសម្រាប់គ្រប់គ្រង ដោយយោងលើសេចក្ដីណែនាំ សាលាមិនគ្រប់កម្រិតពុំមានកូតាផ្ដល់ឱ្យមានបណ្ណារក្សទេ។ ដោយឡែកនៅខេត្តកោះកុង សាលាអនុវិទ្យាល័យសរុបចំនួន ១៩ពុំមានបណ្ណាល័យទាំងអស់ ដោយសារសាលាចំនួន១៥ ជាសាលាមិនគ្រប់កម្រិត និងសាលាចំនួន៤ផ្សេងទៀតខ្វះបន្ទប់។ នៅកម្រិតអនុវិទ្យាល័យពុំសូវមានការអង្គការ ឬដៃគូអភិវឌ្ឍន៍ ឧបត្ថម្ភគាំទ្រទេ ដែលជាហេតុធ្វើឱ្យបណ្ណាល័យដំណើរការមិនសូវបានល្អ ដោយគ្មានធនធានសម្ភារៈ និងឯកសារគ្រប់គ្រាន់។ ចំពោះការគ្រប់គ្រងឯកសារ និងកត់ត្រាប្រើប្រាស់ដោយដៃនៅឡើយ។ បច្ចុប្បន្នមានអង្គការមូលនិធិអាស៊ី និងអង្គការខេប បានចូលរួមជួយដល់សាលាអនុវិទ្យាល័យ ក្នុងការផ្ដល់សៀវភៅជាភាសាអង់គ្លេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ក៏បានចូលរួមសាងសង់អគារបណ្ណាល័យ បំពាក់ធនធានសម្ភារបរិក្ខារ ធនធានឯកសារ និងការបំប៉នបណ្ណារក្សដល់សាលាកម្រិតអនុវិទ្យាល័យមួយចំនួននៅខេត្តកណ្ដាល កំពង់ធំ កំពង់ស្ពឺ តាកែវ បាត់ដំបង ពោធិ៍សាត់ ព្រៃវែង និងស្វាយរៀង ផងដែរ។ លើសពីនេះទៀត ជារៀងរាល់ឆ្នាំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានលើកគម្រោងថវិកាមួយចំនួនសម្រាប់ផ្គត់ផ្គង់គ្រឿងសង្ហារិម (ធ្នើរ តុអាន តុបណ្ណារក្ស) ដាក់តាមសាលាអនុវិទ្យាល័យ ប៉ុន្តែពុំទាន់បានទូលំទូលាយនៅឡើយ ដោយសារថវិកាមានកម្រិតតិចតួច។

## តារាងទី៣៖ ព័ត៌មានស្ថិតិបណ្ណាល័យអនុវិទ្យាល័យ ឆ្នាំ២០២០

| ព័ត៌មានស្ថិតិបណ្ណាល័យអនុវិទ្យាល័យឆ្នាំសិក្សា ២០១៩-២០២០ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | រាជធានី/ខេត្ត | បរិយាយ | | | | |
| | | ចំនួនសាលា | ចំនួនបណ្ណាល័យ | ដំណើរការ | ចំនួនបណ្ណារក្ស | ធ្លាប់បំប៉ន |
| ១ | បន្ទាយមានជ័យ | 54 | 43 | 23 | 19 | 0 |
| ២ | បាត់ដំបង | 96 | 38 | 35 | 49 | 27 |
| ៣ | កំពង់ចាម | 81 | 18 | 18 | 24 | 0 |
| ៤ | កំពង់ឆ្នាំង | 61 | 23 | 17 | 13 | 1 |
| ៥ | កំពង់ស្ពឺ | 72 | 26 | 21 | 21 | 2 |
| ៦ | កំពង់ធំ | 67 | 34 | 33 | 11 | 0 |
| ៧ | កំពត | 76 | 70 | 70 | 76 | 8 |
| ៨ | កណ្តាល | 102 | 93 | 93 | 61 | 11 |
| ៩ | កែប | 4 | 4 | 4 | 7 | 1 |
| ១០ | កោះកុង | 19 | 0 | 0 | 0 | 0 |
| ១១ | ក្រចេះ | 43 | 20 | 10 | 0 | 0 |
| ១២ | មណ្ឌលគិរី | 8 | 8 | 0 | 0 | 0 |
| ១៣ | ឧត្តរមានជ័យ | 29 | 6 | 0 | 0 | 0 |
| ១៤ | ប៉ៃលិន | 7 | 4 | 3 | 3 | 0 |
| ១៥ | រាជធានីភ្នំពេញ | 27 | 24 | 20 | 21 | 1 |
| ១៦ | ព្រះសីហនុ | 18 | 14 | 5 | 5 | 2 |
| ១៧ | ព្រះវិហារ | 47 | 40 | 18 | 6 | 1 |
| ១៨ | ព្រៃវែង | 92 | 43 | 43 | 44 | 44 |
| ១៩ | ពោធិ៍សាត់ | 44 | 38 | 21 | 23 | 8 |
| ២០ | រតនគិរី | 16 | 9 | 8 | 8 | 1 |
| ២១ | សៀមរាប | 82 | 58 | 45 | 25 | 1 |
| ២២ | ស្ទឹងត្រែង | 30 | 30 | 4 | 5 | 0 |
| ២៣ | ស្វាយរៀង | 54 | 45 | 25 | 30 | 8 |
| ២៤ | តាកែវ | 67 | 62 | 54 | 48 | 7 |
| ២៥ | ត្បូងឃ្មុំ | 52 | 18 | 18 | 4 | 0 |
| **សរុប** | | 1248 | 768 | 588 | 503 | 123 |

**ប្រភព៖ អ្នកនិពន្ធ**

### រូបភាពទី៤៖ ស្ថិតិបណ្ណាល័យអនុវិទ្យាល័យ ឆ្នាំ២០២០




ប្រភព៖ អ្នកនិពន្ធ

### រូបភាពទី៥៖ ស្ថិតិបណ្ណាល័យដំណើរការនៅអនុវិទ្យាល័យ ឆ្នាំ២០២០




ប្រភព៖ អ្នកនិពន្ធ

## ២.២.២. ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ

បណ្ណាល័យអនុវិទ្យាល័យ មានការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ នៅមានកម្រិតតិចតួចនៅឡើយ ដែលធ្វើឱ្យបណ្ណាល័យមិនសូវមានដំណើរការ។ ចំពោះការរៀបចំនៅមិនទាន់សមស្របទៅនឹងកម្រិតរបស់សិស្ស ដែលធ្វើឱ្យចំនួនអ្នកអានមានតិចតួច។ តាមទិន្នន័យដែលទទួលបានឃើញថា មានបណ្ណាល័យចំនួន២៩០ ស្មើនឹង៣៨ភាគរយ តែប៉ុណ្ណោះដែលមានសម្ភារៈ និងបរិក្ខារ អាចរៀបចំបណ្ណាល័យបានល្អបង្គួរ និងដំណើរការទៅបាន ដោយឡែកចំពោះបណ្ណាល័យចំនួន៤៧៨ ស្មើនឹង៦២ភាគរយ គឺនៅខ្វះខាតធនធានសម្ភារៈ និងបរិក្ខារនៅឡើយ។ ដូច្នេះដើម្បីឱ្យបណ្ណាល័យមានសម្ភារៈ និងបរិក្ខារគ្រប់គ្រាន់ ទាមទារការចូលរួមរបស់គណៈគ្រប់គ្រងសាលាជាការចាំបាច់បំផុត ក្នុងការផ្សព្វផ្សាយ និងស្វែងរកការឧបត្ថម្ភបន្ថែមទៀតពី សប្បុរជន ដៃគូអភិវឌ្ឍន៍ សហគមន៍ និងប្រើប្រាស់ថវិការបស់សាលាផ្ទាល់ ដើម្បីធ្វើឱ្យបណ្ណាល័យអាចល្អប្រសើរបាន។

## ២.២.៣. ការបំពាក់ធនធានឯកសារ

ការបំពាក់ឯកសារនៅក្នុងបណ្ណាល័យមានតិចតួច មិនឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សរៀនសូត្រនៅកម្រិតអនុវិទ្យាល័យ ដែលធ្វើឱ្យបណ្ណាល័យពុំសូវមានសិស្សចូលប្រើប្រាស់។ បើតាមទិន្នន័យដែលទទួលបានក្នុងចំណោមបណ្ណាល័យដំណើរការចំនួន ៥៨៨ មានបណ្ណាល័យចំនួន២៣៥ ស្មើនឹង ៤០ភាគរយ ដែលមានឯកសារអានបន្ថែមកម្រិតមធ្យមសម្រាប់ដាក់ក្នុងបណ្ណាល័យឱ្យសិស្សប្រើប្រាស់ ដោយឡែកបណ្ណាល័យចំនួន ៣៥៣ ស្មើនឹង៦០ភាគរយ ពុំសូវមានឯកសារអានបន្ថែមទេ ដោយឯកសារភាគច្រើនគឺសៀវភៅសិក្សាគោល។ បច្ចុប្បន្នមានអង្គការមួយចំនួនបានជួយផ្តល់សៀវភៅអានបន្ថែមជាភាសាអង់គ្លេសសម្រាប់កម្រិតអនុវិទ្យាល័យផងដែរដូចជា អង្គការមូលនិធិអាស៊ី និងអង្គការរូមធូរីដ ជាដើម។ ចំពោះការបំពាក់សៀវភៅភាសាបរទេសក្នុងបណ្ណាល័យនៅតាមជនបទពុំសូវទទួលបានផលទេ ដោយសិស្សភាគច្រើនពុំមានចំណេះដឹងភាសាបរទេសអាចអាន និងយល់អត្ថន័យបាន ដែលធ្វើឱ្យសៀវភៅមួយចំនួនស្លាប់ (គ្មានអ្នកប្រើប្រាស់)។

## ២.២.៤. ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ

ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យនៅអនុវិទ្យាល័យ ក៏មិនខុសពីកម្រិតបឋមសិក្សាដែរ ដោយត្រូវជ្រើសរើសចេញពីគ្រូបង្រៀនក្របខណ្ឌ។ បណ្ណារក្សភាគច្រើន គឺជាមនុស្សមានវ័យចំណាស់ សុខភាពមិនសូវល្អ ព្រមទាំងអសកម្ម ចំពោះគ្រូបង្រៀនដែលមានកម្លាំងពេញលេញ មានសុខភាពល្អ គឺមិនចង់ធ្វើជាបណ្ណារក្សទេ ដោយលើកហេតុផលថាការងារជាបណ្ណារក្ស គឺត្រូវធ្វើការពេញម៉ោង ហើយពិបាកទៀត។ តាម

ទិន្នន័យដែលទទួលបាន ក្នុងចំណោមបណ្ណាល័យចំនួន ៧៦៨ មានបណ្ណារក្សចំនួន៥០៣ នាក់ ប៉ុណ្ណោះ នេះបង្ហាញឱ្យឃើញថា ចំនួនបណ្ណារក្ស មានតិចជាងចំនួនបណ្ណាល័យ។ បើយើងប្រៀបធៀបចំនួនបណ្ណាល័យដែលដំណើរការមានចំនួន៥៨៨បណ្ណាល័យ ទៅនឹងចំនួនបណ្ណារក្សសរុបចំនួន៥០៣ នាក់ នោះចំនួនបណ្ណារក្សក៏តិចជាងចំនួនបណ្ណាល័យផងដែរ ដូច្នេះបញ្ជាក់ឱ្យហើយថា ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យនៅកម្រិតអនុវិទ្យាល័យមានបញ្ហាធ្ងន់ធ្ងរ ដែលធ្វើឱ្យបណ្ណាល័យមិនដំណើរការ និងបើកទ្វាមិនទៀងទាត់។ ការកំណត់ចំនួនបណ្ណារក្សនៅតាមសាលាក៏មិនទាន់មានការអនុវត្តឱ្យបានដូចគ្នាទូទាំងប្រទេសនៅឡើយ ដោយខេត្តខ្លះប្រើប្រាស់ស្តង់ដារបណ្ណាល័យមធ្យមសិក្សា និងខេត្តខ្លះទៀតប្រើប្រាស់សេចក្តីណែនាំលេខ២០ អយក.សណន។ បើងាកមកមើលការបំប៉នសមត្ថភាពបណ្ណារក្សវិញ កាន់តែមានបញ្ហាធ្ងន់ធ្ងរថែមទៀត ដោយបណ្ណារក្សសរុបចំនួន ៥០៣ នាក់ មានតែបណ្ណារក្សចំនួន ១២៣ នាក់ ស្មើនឹង ២៤ភាគរយ តែប៉ុណ្ណោះដែលធ្លាប់ទទួលបានការបំប៉នសមត្ថភាពផ្នែកបណ្ណាល័យ។ ដោយឡែក បណ្ណារក្សចំនួន ៣៨០នាក់ ស្មើនឹង ៧៦ភាគរយ គឺបំពេញការងារដោយពុំមានចំណេះដឹងផ្នែកគ្រប់គ្រងបណ្ណាល័យ ដែលធ្វើឱ្យការរៀបចំ ការគ្រប់គ្រងមិនសូវមានដំណើរការល្អ។ ក្នុងនោះមានខេត្តចំនួនបី ដែលមានបណ្ណាល័យ ប៉ុន្តែគ្មានបណ្ណារក្សគ្រប់គ្រង គឺខេត្តក្រចេះ មណ្ឌលគិរី និងខេត្តឧត្តរមានជ័យ។

**រូបភាពទី៦៖ ស្ថិតិបណ្ណារក្សអនុវិទ្យាល័យ ឆ្នាំ២០២០**




**ប្រភព៖ អ្នកនិពន្ធ**

## ២.៣. បណ្ណាល័យវិទ្យាល័យ

### ២.៣.១. ស្ថានភាពបណ្ណាល័យ

បច្ចុប្បន្នសាលារៀនកម្រិតវិទ្យាល័យ (សាលារៀនសាធារណៈ) នៅកម្ពុជា មានចំនួន ៥៤៤ សាលា ដែលក្នុងនោះសាលាដែលមានបណ្ណាល័យសរុបចំនួន ៤៨៤សាលា ស្មើនឹង ៨៩ភាគរយ ហើយបណ្ណាល័យដែលមានដំណើរការមានចំនួន៤៥៧ ស្មើនឹង ៩៤ភាគរយ នៃចំនួនបណ្ណាល័យសរុប។ នេះបង្ហាញឱ្យឃើញថា នៅកម្រិតវិទ្យាល័យបណ្ណាល័យមានសកម្មភាពច្រើន សម្រាប់បម្រើដល់ការសិក្សារបស់សិស្សានុសិស្ស។ បណ្ណាល័យនៅកម្រិតវិទ្យាល័យលក្ខណៈជាអគារ បន្ទប់ និងក្នុងទីចាត់ការតែប៉ុណ្ណោះ ដែលខុសពីកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ ដែលមានជ្រុងថ្នាក់ និងចល័ត។ ទោះជាបណ្ណាល័យមានចំនួនច្រើនបើប្រៀបធៀបទៅនឹងចំនួនសាលាក៏ដោយ ប៉ុន្តែបណ្ណាល័យភាគច្រើននៅមានលក្ខណៈតូចចង្អៀតបើធៀបទៅនឹងចំនួនសិស្ស ដែលធ្វើឱ្យសិស្សមិនអាចប្រើប្រាស់បានទូលំទូលាយ។ ការជំរុញឱ្យសិស្សចូលបណ្ណាល័យ ពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ នៅមានកម្រិតទាប ដោយយោងតាមស្ថិតិចូលប្រើប្រាស់របស់គ្រូ។ ការមិនចូលរួមពីគ្រូបង្រៀនធ្វើឱ្យបណ្ណាល័យក៏មិនសូវមានប្រសិទ្ធភាព តាមរយៈការដាក់កិច្ចការឱ្យសិស្សចូលស្រាវជ្រាវក្នុងបណ្ណាល័យ និងការរៀបចំស្នាដៃនៃមុខវិជ្ជាបង្រៀនរបស់ខ្លួន ដើម្បីតម្កល់ទុកក្នុងបណ្ណាល័យឱ្យសិស្សស្រាវជ្រាវបន្ថែម។ ចំពោះការគ្រប់គ្រង និងការកត់ត្រាផ្សេងៗ ភាគច្រើននៅប្រើប្រាស់ដោយដៃផងដែរ។ កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបណ្ណាល័យតាមកុំព្យូទ័រ ដាក់សាកល្បងតាមសាលាមួយចំនួនប៉ុន្តែពុំមានប្រសិទ្ធភាព ដោយសារសាលាខ្វះអ្នកជំនាញ ខ្វះការថែទាំ រួមផ្សំនឹងបណ្ណារក្សគ្មានចំណេះដឹងផ្នែកកុំព្យូទ័រ ធ្វើឱ្យកម្មវិធីមិនអាចប្រើប្រាស់បាន និងត្រូវបោះបង់ចោល។ បណ្ណាល័យដែលមានដំណើរការល្អមានតែបណ្ណាល័យសាលាធនធាន ដែលមានគម្រោងអភិវឌ្ឍ ដោយមានការបំពាក់គ្រឿងសង្ហារិម និងធានធានឯកសារ ចំពោះសាលាដែលមិនមែនជាសាលាធនធានមិនសូវមានដំណើរការទេ ដោយសារខ្វះខាតគ្រឿងសង្ហារិម និងធនធានឯកសារ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានកម្មវិធីការប្រឡងប្រណាំង នាយកសាលាល្អ និងអង្គភាពផ្តល់សេវាសាធារណៈគំរូ បានជំរុញឱ្យសាលាជាច្រើនបានខិតខំប្រឹងប្រែងកែលម្អបរិស្ថានសាលារៀនដោយរួមទាំងបណ្ណាល័យផងដែរ ព្រោះបណ្ណាល័យក៏ជាផ្នែកមួយសម្រាប់ការវាយតម្លៃដាក់ពិន្ទុ ដើម្បីទទួលបានជ័យលាភីក្នុងការប្រឡងប្រណាំងនោះដែរ។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ ក្រោមជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយអភិវឌ្ឍន៍ វិទ្យាល័យធនធានចំនួន៥០សាលា និងវិទ្យាល័យបណ្តាញចំនួន៨៦សាលា នៅទូទាំង២៥ រាជធានី ខេត្ត ដោយក្នុងនោះក៏មានការអភិវឌ្ឍបណ្ណាល័យផងដែរ។

## តារាងទី៤៖ ព័ត៌ស្ថិតិបណ្ណាល័យវិទ្យាល័យ ឆ្នាំ២០២០

| ព័ត៌មានស្ថិតិបណ្ណាល័យវិទ្យាល័យឆ្នាំសិក្សា ២០១៩-២០២០ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | រាជធានី/ខេត្ត | បរិយាយ | | | | |
| | | ចំនួនសាលា | ចំនួនបណ្ណាល័យ | ដំណើរការ | ចំនួនបណ្ណារក្ស | ធ្លាប់បំប៉ន |
| ១ | បន្ទាយមានជ័យ | 30 | 29 | 25 | 33 | 3 |
| ២ | បាត់ដំបង | 28 | 25 | 21 | 40 | 17 |
| ៣ | កំពង់ចាម | 43 | 33 | 33 | 77 | 2 |
| ៤ | កំពង់ឆ្នាំង | 16 | 16 | 15 | 27 | 6 |
| ៥ | កំពង់ស្ពឺ | 24 | 22 | 20 | 38 | 8 |
| ៦ | កំពង់ធំ | 25 | 18 | 18 | 35 | 12 |
| ៧ | កំពត | 24 | 24 | 23 | 44 | 8 |
| ៨ | កណ្តាល | 39 | 39 | 39 | 90 | 32 |
| ៩ | កែប | 2 | 2 | 2 | 4 | 2 |
| ១០ | កោះកុង | 12 | 5 | 5 | 12 | 2 |
| ១១ | ក្រចេះ | 12 | 11 | 11 | 14 | 3 |
| ១២ | មណ្ឌលគិរី | 5 | 5 | 1 | 1 | 0 |
| ១៣ | ឧត្តរមានជ័យ | 9 | 7 | 6 | 9 | 0 |
| ១៤ | ប៉ៃលិន | 2 | 2 | 2 | 4 | 1 |
| ១៥ | រាជធានីភ្នំពេញ | 40 | 39 | 39 | 76 | 12 |
| ១៦ | ព្រះសីហនុ | 9 | 9 | 9 | 11 | 4 |
| ១៧ | ព្រះវិហារ | 17 | 11 | 8 | 7 | 3 |
| ១៨ | ព្រៃវែង | 32 | 32 | 32 | 64 | 64 |
| ១៩ | ពោធិ៍សាត់ | 16 | 14 | 12 | 30 | 11 |
| ២០ | រតនគិរី | 11 | 11 | 10 | 11 | 4 |
| ២១ | សៀមរាប | 41 | 35 | 34 | 46 | 10 |
| ២២ | ស្ទឹងត្រែង | 8 | 5 | 3 | 7 | 1 |
| ២៣ | ស្វាយរៀង | 20 | 19 | 19 | 34 | 6 |
| ២៤ | តាកែវ | 52 | 52 | 51 | 89 | 22 |
| ២៥ | ត្បូងឃ្មុំ | 27 | 19 | 19 | 27 | 0 |
| **សរុប** | | 544 | 484 | 457 | 830 | 233 |

**ប្រភព៖ អ្នកនិពន្ធ**

## រូបភាពទី៧៖ ស្ថិតិបណ្ណាល័យវិទ្យាល័យ ឆ្នាំ២០២០




**ប្រភព៖ អ្នកនិពន្ធ**

## រូបភាពទី៨៖ ស្ថិតិបណ្ណាល័យដំណើរការនៅវិទ្យាល័យ ឆ្នាំ២០២០




**ប្រភព៖ អ្នកនិពន្ធ**

### ២.៣.២. ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ

បណ្ណាល័យកម្រិតវិទ្យាល័យមានការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ បានល្អប្រសើរ សមស្របទៅនឹងកម្រិតអាយុរបស់សិស្ស ប៉ុន្តែមិនទាន់បានគ្រប់បណ្ណាល័យនៅឡើយ។ ក្នុងចំណោមបណ្ណាល័យចំនួន៤៨៤ មានបណ្ណាល័យចំនួន២៥០ ស្មើនឹង៥២ ភាគរយ ដែលមានសម្ភារៈ និងបរិក្ខារ អាចរៀបចំជាបណ្ណាល័យល្អបង្គួរ ប៉ុន្តែបណ្ណាល័យចំនួន២៣៤ ស្មើនឹង ៤៨ភាគរយ មិនទាន់មានសម្ភារៈ និងបរិក្ខារសមស្របនៅឡើយ។ ចំពោះការប្រើប្រាស់ធ្នើរមិនទាន់បានល្អប្រសើរទេ ដោយសាលានីមួយៗ បានរៀបចំទៅតាមលទ្ធភាពរបស់ខ្លួនរៀងៗខ្លួន សាលាខ្លះប្រើប្រាស់ទូសម្រាប់ដាក់សៀវភៅ ដែលមិនសមស្របទៅតាមការណែនាំឱ្យប្រើប្រាស់ធ្នើរមុខពីរ ឬធ្នើរមុខមួយ ក្នុងស្តង់ដារបណ្ណាល័យមធ្យមសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា។

### ២.៣.៣. ការបំពាក់ធនធានឯកសារ

ចំពោះការបំពាក់ធនធានឯកសារនៅបណ្ណាល័យកម្រិតវិទ្យាល័យ សង្កេតឃើញថា បានបំពាក់ល្អបង្គួរដែរ ប៉ុន្តែនៅខ្វះខាតឯកសារដែលគាំទ្រដល់ការសិក្សារបស់សិស្ស ដូចជាសៀវភៅអត្រាកំណៃ សៀវភៅជំនួយស្មារតី និងសៀវភៅផ្សេងៗទៀតដែលទាក់ទងនឹងកម្មវិធីសិក្សានៅកម្រិតវិទ្យាល័យ។ បណ្ណាល័យនៃសាលាធនធានត្រូវបានមើលឃើញថាមានឯកសារច្រើនជាងសាលាផ្សេងៗ ដោយសារសាលាធនធានមានការឧបត្ថម្ភទៅលើការទិញសៀវភៅដាក់ក្នុងបណ្ណាល័យ។ ការស្វែងរកឯកសារដាក់ក្នុងបណ្ណាល័យ គឺជារឿងសំខាន់ដែលគណៈគ្រប់គ្រងសាលាគួរយកចិត្តទុកដាក់ ដោយត្រូវស្វែងរកតាមមធ្យោបាយផ្សេងៗ ដូចជា ដៃគូអភិវឌ្ឍន៍ សប្បុរសជន អតីតសិស្ស និងសហគមន៍ជាដើម។ សាលាមួយចំនួនបានប្រើប្រាស់ថវិការបស់សាលាមួយចំនួនសម្រាប់ទិញសៀវភៅដាក់ក្នុងបណ្ណាល័យជារៀងរាល់ឆ្នាំ ដែលធ្វើឱ្យឯកសារមានការកើនឡើង និងសម្បូរបែបផងដែរ។

### ២.៣.៤. ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ

ការជ្រើសរើសបណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យនៅវិទ្យាល័យ ក៏មិនខុសពីសាលាបឋមសិក្សា និងអនុវិទ្យាល័យដែរ គឺជ្រើសរើសចេញពីគ្រូបង្រៀនដែលមានសុខភាពទន់ខ្សោយ និងគ្រូដែលពុំសូវសកម្ម ព្រមទាំងពុំមានចំណេះដឹងផ្នែកគ្រប់គ្រងបណ្ណាល័យ។ ក្នុងស្តង់ដារបណ្ណាល័យមធ្យមសិក្សា ការជ្រើសរើសបណ្ណារក្សត្រូវមានលក្ខណៈសម្បត្តិ ជាច្រើនដូចជា គ្រូបង្រៀនក្របខណ្ឌដែលមានទីលំនៅក្នុងមូលដ្ឋាន ស្រឡាញ់ការងារបណ្ណាល័យ អាកប្បកិរិយាល្អ ចូលចិត្តអាន ស្រាវជ្រាវ និងគំនិតច្នៃប្រឌិតខ្ពស់ មានសុខភាពល្អ មានទំនាក់ទំនងល្អ មានចំណេះដឹងផ្នែកភាសាអង់គ្លេស និងកុំព្យូទ័រ និងអាយុក្រោម៥០ឆ្នាំ។ ម្យ៉ាងទៀតបណ្ណារក្សភាគច្រើន

ពុំធ្លាប់បានទទួលបានការបំប៉នការងារបណ្ណាល័យដែលធ្វើឱ្យការគ្រប់គ្រងមិនសូវបានល្អ ដោយបណ្ណារក្សសរុបមានចំនួន៨៣០ នាក់ មានបណ្ណារក្សចំនួន២៣៣នាក់ ស្មើនឹង២៨ភាគរយ ប៉ុណ្ណោះដែលធ្លាប់ទទួលបានការបំប៉នសមត្ថភាពទាក់ទងនឹងការងារបណ្ណាល័យ។ គ្រូបង្រៀនដែលមានចំណេះដឹងទូលំទូលាយ និងមានសុខភាពល្អ ភាគច្រើនមិនចូលចិត្តការងារបណ្ណាល័យទេ ព្រមទាំងមិនសូវមានការគាំទ្រ និងជំរុញសិស្សឱ្យចូលប្រើប្រាស់ផងដែរ។

**រូបភាពទី៩៖ ស្ថិតិបណ្ណារក្សនៅវិទ្យាល័យ ឆ្នាំ២០២០**




**ប្រភព៖ អ្នកនិពន្ធ**

# ជំពូកទី៣
# ការវិភាគលទ្ធផលនៃរបកគំហើញលើការអភិវឌ្ឍបណ្ណាល័យនៅកម្ពុជា

## ៣.១. បញ្ហាប្រឈម

### ៣.១.១. ធនធានមនុស្ស (បណ្ណារក្ស)

តាមការសង្កេតឃើញ រួមជាមួយទិន្នន័យដែលប្រមូលបាន បង្ហាញឱ្យឃើញថា បញ្ហាប្រឈមធំបំផុត គឺធនធានមនុស្ស (បណ្ណារក្ស)។ បណ្ណាល័យសាលារៀនដំណើរការទៅបាន គឺត្រូវមានបណ្ណារក្ស ឬអ្នកគ្រប់គ្រងច្បាស់លាស់ ក្នុងការមើលការខុសត្រូវ រៀបចំ ថែរក្សា ផ្សព្វផ្សាយ និងបម្រើសេវាកម្មផ្សេងៗ ដល់អ្នកអានអ្នកស្រាវជ្រាវ។ ការអនុវត្តនិយាមប្រើប្រាស់បណ្ណារក្សនៅតាមសាលារៀនពុំឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងដោយសារសាលាភាគច្រើនខ្វះបណ្ណារក្ស និងការមិនទទួលបានប្រាក់ឧបត្ថម្ភបន្ថែម ធ្វើឱ្យបណ្ណាល័យដំណើរការមិនបានពេញលេញ។ ម្យ៉ាងទៀតបណ្ណារក្សភាគច្រើនមានសុខភាពមិនសូវល្អ វ័យចំណាស់ អសកម្ម និងមានចំណេះដឹងមិនទូលំទូលាយ ធ្វើឱ្យការបំពេញការងារមិនបានពេញលេញ និងគ្មានប្រសិទ្ធភាព។ បណ្ណាល័យបឋមសិក្សាក្នុងរាជធានី ខេត្ត ចំនួន១៤ ដូចជា ខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ធំ កំពត កែប កោះកុង ក្រចេះ មណ្ឌលគិរី ភ្នំពេញ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង និងខេត្តតាកែវ ពុំមានបណ្ណារក្សគ្រប់គ្រាន់ឆ្លើយតបទៅនឹងចំនួនបណ្ណាល័យនៅឡើយ។ ចំពោះខេត្តចំនួន១១ ផ្សេងទៀត ទោះបីជាចំនួនបណ្ណារក្សមានស្មើ ឬច្រើនជាងចំនួនបណ្ណាល័យក៏ដោយ ក៏មានបណ្ណាល័យចំនួនមិនដំណើរការផងដែរ។ ចំពោះបណ្ណាល័យអនុវិទ្យាល័យ បញ្ហាគ្មានបណ្ណារក្សមានរហូតដល់១៦ខេត្ត និងខេត្តចំនួន៣ ដែលគ្មានបណ្ណារក្ស។ ដោយឡែកបណ្ណាល័យវិទ្យាល័យមានតែខេត្តព្រះវិហារ តែមួយប៉ុណ្ណោះដែលចំនួនបណ្ណារក្សតិចជាងចំនួនបណ្ណាល័យ។

### ៣.១.២. ធនធានឯកសារ

ការបំពាក់ឯកសារនៅតាមបណ្ណាល័យពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សនៅតាមកម្រិតសិក្សាពីបឋមសិក្សារហូតដល់វិទ្យាល័យនៅឡើយ ដែលជាហេតុធ្វើឱ្យកុមារ និងសិស្ស មិនសូវចាប់អារម្មណ៍ចំពោះបណ្ណាល័យ។ ឯកសារនៅកម្រិតបឋមសិក្សាភាគច្រើនជារឿងនិទាន ដែលធ្វើឱ្យកុមារអាន ឬស្តាប់ទៅឆាប់ជក់ចិត្ត ហើយក៏ឆាប់ធុញទ្រាន់នៅពេលសៀវភៅរឿងទាំងនោះត្រូវបានអាន ឬស្តាប់រួចហើយ។ ចំពោះបណ្ណាល័យកម្រិតអនុវិទ្យាល័យ កាន់តែពុំសូវមានឯកសារសម្រាប់ជំនួយក្នុងការរៀន និងបង្រៀន ដែលធ្វើឱ្យបណ្ណាល័យជាច្រើនមិនសូវដំណើរការ ឬបិទទ្វារតែម្តង។ ចំពោះការផ្គត់ផ្គង់ឯកសារនៅលើទីផ្សារ ក៏មិនសូវសម្បូរបែប ដែលធ្វើ

ឱ្យមានការលំបាកក្នុងការស្វែងរកសម្រាប់ដាក់ក្នុងបណ្ណាល័យផងដែរ។ ដោយឡែកចំពោះបណ្ណាល័យកម្រិតវិទ្យាល័យវិញក៏មានបញ្ហាខ្លះដែរ ដោយសារឯកសារភាគច្រើនពុំឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សក្នុងការរៀនសូត្រដែលទាមទារឱ្យមានការយកចិត្តទុកដាក់ក្នុងការស្វែងរកឯកសារដែលបំពេញតម្រូវការរបស់សិស្ស ក្នុងការជួយគាំទ្រ និងពង្រីកចំណេះដឹងរបស់សិស្ស។

### ៣.១.៣. ធនធានសម្ភារៈ និងបរិក្ខារ

ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារ ភាគច្រើនពុំទាន់សមស្របទៅនឹងកម្រិតរបស់សិស្សតាមកម្រិតនៅឡើយ។ ធនធានសម្ភារៈ និងបរិក្ខារមិនគ្រប់គ្រាន់ ធ្វើឱ្យរៀបចំបណ្ណាល័យមិនបានល្អ គ្មានភាពទាក់ទាញដល់កុមារ អ្នកអាន និងអ្នកស្រាវជ្រាវ ឱ្យចូលប្រើប្រាស់បណ្ណាល័យ។

### ៣.១.៤. ថវិកាតាមសាលា

ការផ្តល់ថវិកាដំណើរការរបស់សាលា មានកម្រិតតិចតួចដែលមិនអាចអភិវឌ្ឍបណ្ណាល័យបាន ដែលត្រូវទាមទារឱ្យមានការពិនិត្យឡើងវិញ សម្រាប់ការចំណាយលើផ្នែកបណ្ណាល័យ សម្រាប់រៀបចំបណ្ណាល័យមួយដែលមានសោភ័ណភាព គុណភាព និងដំណើរការទៅបានយូរអង្វែង។

### ៣.១.៥. ការគាំទ្របណ្ណាល័យ

ការគាំទ្របណ្ណាល័យ គឺជាផ្នែកមួយដ៏សំខាន់ ដែលអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ មិនគួរមើលរំលង ជាពិសេស គណៈគ្រប់គ្រងសាលា ដែលជាអ្នកប្រតិបត្តិ និងទទួលបន្ទុកការងារផ្ទាល់។ ការមិនគាំទ្រ និងចូលរួមពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ បណ្ណារក្ស សហគមន៍ គឺជាភាពខ្វះខាត ដែលធ្វើឱ្យបណ្ណាល័យមិនដំណើរការ និងឈានទៅរកការបិទទ្វារ។

### ៣.១.៦. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យ

តាមទិន្នន័យបង្ហាញថា ភាពខ្វះខាតបន្ទប់ ឬអគារធ្វើជាបណ្ណាល័យ នៅតែជាបញ្ហាផងដែរសម្រាប់អភិវឌ្ឍបណ្ណាល័យតាមសាលារៀន។ សាលាសរុបចំនួន៩,០៧៥ សាលាដែលមានបណ្ណាល័យ ចំនួន៥,៧៤០ ក្នុងនោះបណ្ណាល័យជាអគារចំនួន៥៣៥ បណ្ណាល័យជាបន្ទប់ចំនួន៤,២១៥ បណ្ណាល័យក្នុងទីចាត់ការ ចំនួន ៨៩៥ បណ្ណាល័យជ្រុងថ្នាក់ចំនួន៨៩ និងបណ្ណាល័យចល័តចំនួន៦។ នេះបញ្ជាក់ឱ្យឃើញថា សាលាដែលគ្មានបណ្ណាល័យចំនួន៣,៣៣៥ ស្មើនឹង៣៧ភាគរយ ដែលបណ្តាលមកពីខ្វះបន្ទប់ និងអគារ។

## ៣.២. ដំណោះស្រាយ

### ៣.២.១. ធនធានមនុស្ស (បណ្ណារក្ស)

ការដោះស្រាយបញ្ហាធនធានមនុស្ស (បណ្ណារក្ស) គឺជាអាទិភាពទីមួយ សម្រាប់ឱ្យបណ្ណាល័យអាចដំណើរការឈានទៅរកការអភិវឌ្ឍ និងនិរន្តរភាព។ បណ្ណារក្ស គឺជាអ្នកដែលអាចធ្វើឱ្យបណ្ណាល័យរស់ ឬស្លាប់ ដូច្នេះបណ្ណារក្ស ត្រូវជាមនុស្សដែលស្រឡាញ់ចូលចិត្តការងារពាក់ព័ន្ធនឹងបណ្ណាល័យ ដូចជាស្រឡាញ់ការអាន មានទំនាក់ទំនងល្អ និងចំណេះដឹងទូលំទូលាយ។ ដំណោះស្រាយក្នុងរយៈពេលមធ្យម ការជ្រើសរើសបណ្ណារក្ស ចេញពីគ្រូបង្រៀនក្របខណ្ឌ ដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងមូលដ្ឋាន មានសុខភាពល្អ ចំណេះដឹងទូលំទូលាយ សកម្មការងារ ទំនាក់ទំនងល្អ មានចំណេះដឹងផ្នែកភាសាបរទេស និងមានមនសិការវិជ្ជាជីវៈខ្ពស់ ដើម្បីយកទៅបំប៉នសមត្ថភាពផ្នែកគ្រប់គ្រងបណ្ណាល័យ។ ដំណោះស្រាយរយៈពេលវែង ត្រូវរៀបចំឱ្យមានការប្រឡងជ្រើសរើសបណ្ណារក្សក្របខណ្ឌ ដើម្បីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជា បណ្ណារក្ស ពិតប្រាកដ នៅតាមវិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោលស្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការ។

### ៣.២.២. ធនធានឯកសារ

ការបំពាក់ឯកសារក្នុងបណ្ណាល័យ គឺជាអទិភាពទីពីរ សម្រាប់ឱ្យបណ្ណាល័យដំណើរការ មានអ្នកអានចូលប្រើប្រាស់ជាប្រចាំ។ ឯកសារប្រៀបដូចជាចំណីអាហារដ៏មានឱជារសសម្រាប់អ្នកសិក្សាគ្រប់កម្រិត ប្រសិនបើបណ្ណាល័យសម្បូរឯកសារ ដែលបំពេញតម្រូវការរបស់អ្នកអានគ្រប់សមាសភាពបាន នោះបណ្ណាល័យកាន់តែខ្លាំង និងមានសក្តានុពល។ ដំណោះស្រាយរយៈពេលមធ្យម ត្រូវស្វែងរកឯកសារដែលត្រូវកម្រិតរបស់បណ្ណាល័យបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ឱ្យបានច្រើនដាក់ក្នុងបណ្ណាល័យ។ ដំណោះស្រាយរយៈពេលវែង ត្រូវលើកទឹកចិត្ត ជំរុញឱ្យមានការតែងនិពន្ធសៀវភៅជំនួយក្នុងការរៀន និងបង្រៀន ស្របតាមកម្មវិធីសិក្សា សម្រាប់កម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ឱ្យកាន់តែសម្បូរបែប។

### ៣.២.៣. ធនធានសម្ភារៈ និងបរិក្ខារ

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវលើកសំណើថវិកា សម្រាប់ផ្គត់ផ្គង់គ្រឿងសង្ហារិម និងបរិក្ខារផ្សេងៗទៅតាមសាលាដែលមានការខ្វះខាត និងកំណត់ចំនួនជាក់លាក់តាមលក្ខណៈរបស់បណ្ណាល័យដែលជាអគារ និងបន្ទប់។ ត្រូវរៀបចំផែនការឱ្យបានច្បាស់សម្រាប់ផ្គត់ផ្គង់សម្ភារៈ និងបរិក្ខារដល់បណ្ណាល័យបឋមសិក្សាចំនួន

ប៉ុន្មាន អនុវិទ្យាល័យចំនួនប៉ុន្មាន និងវិទ្យាល័យចំនួនប៉ុន្មាន ក្នុងមួយឆ្នាំៗ ដើម្បីឱ្យមានប្រសិទ្ធភាព និងសម្រេចបានលទ្ធផលល្អប្រសើរ។ ស្វែងរកជំនួយបន្ថែមពី អង្គការ ដៃគូអភិវឌ្ឍន៍ សប្បុរជន និងស្ថាប័នផ្សេងៗទៀត ដើម្បីចូលរួមគាំទ្រដល់ដល់ការបំពាក់ធនធានសម្ភារៈ និងបរិក្ខារដល់បណ្ណាល័យ។

### ៣.២.៤. ថវិកាតាមសាលា

ពិនិត្យលទ្ធភាពនៃការផ្តល់ថវិកាដំណើរការរបស់សាលា ដោយបញ្ជាក់ខ្ទង់ចំណាយសម្រាប់គាំទ្រដល់បណ្ណាល័យឱ្យបានច្បាស់លាស់ ក្នុងមួយឆ្នាំប៉ុន្មានភាគរយ ព្រមទាំងប្រើប្រាស់ថវិកាឱ្យមានគណនេយ្យភាព។ ផ្តល់ប្រាក់ឧបត្ថម្ភដល់បណ្ណារក្សដែលបម្រើការពីរពេល(២វេន) នៅកម្រិតសាលាបឋមសិក្សា និងប្រាក់ម៉ោងបន្ថែមសម្រាប់បណ្ណារក្សនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ។

### ៣.២.៥. ការគាំទ្របណ្ណាល័យ

រៀបចំបង្កើតគណៈកម្មការគាំទ្រ និងទ្រទ្រង់បណ្ណាល័យ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការដឹកនាំច្បាស់លាស់ សម្រាប់អនុវត្ត និងពិនិត្យតាមដាន។ សម្រាប់ថ្នាក់ជាតិ ក្រសួងអប់រំ ត្រូវបង្កើតអង្គភាពមួយដែលមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ សម្រាប់រៀបចំផែនការសកម្មភាព និងផែនការថវិកា ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពខ្ពស់។ ចំពោះថ្នាក់ក្រោមជាតិ ត្រូវរៀបចំគណៈកម្មការទ្រទ្រង់ពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ សាលាកម្រង គណៈគ្រប់គ្រងសាលា បណ្ណារក្ស អាជ្ញាធរដែនដី និងសហគមន៍។

### ៣.២.៦. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យ

កសាងអគារសិក្សា និងអគារបណ្ណាល័យបន្ថែមទៀត នៅតាមសាលារៀនដែលខ្វះបន្ទប់ ចំនួន៣,៣៣៥ សាលា ដោយពិនិត្យលើលទ្ធភាពថវិកាជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការផ្សេងៗ ព្រមទាំងកំណត់គោលដៅសាលាអាទិភាពផងដែរ។ ដោយឡែកចំពោះសាលាដែលមានបន្ទប់គ្រប់គ្រាន់ប៉ុន្តែមិនគ្រប់កម្រិត ត្រូវជំរុញឱ្យបង្កើតបណ្ណាល័យ ព្រមទាំងរៀបចំឱ្យមានអ្នកគ្រប់គ្រងច្បាស់លាស់។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគទៅលើស្ថានភាពបច្ចុប្បន្ននៃបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា ព្រមទាំងសម្រង់មតិរបស់អ្នកពាក់ព័ន្ធក្នុងវិស័យនេះបង្ហាញឱ្យឃើញថា ក្នុងចំណោមសាលារៀនទាំង៣កម្រិតសិក្សា ចំនួន៩,០៧៥សាលា បណ្ណាល័យមានចំនួន៥,៧៤០ ស្មើនឹង៦៣ភាគរយ ប៉ុន្តែបណ្ណាល័យដំណើរការមានចំនួន៤,៦៥៥ ស្មើនឹង៨១ភាគរយ តែប៉ុណ្ណោះ។ បណ្ណាល័យភាគច្រើនមិនសូវមានដំណើរការល្អ ដោយសារខ្វះធនធានមនុស្ស (បណ្ណារក្ស) សម្រាប់គ្រប់គ្រងបណ្ណាល័យ និងខ្វះការយកចិត្តទុកដាក់ពីគណៈគ្រប់គ្រងសាលា។ ម្យ៉ាងទៀតការជ្រើសរើសគ្រូបង្រៀន ឱ្យធ្វើជាបណ្ណារក្ស គឺជារឿងមួយដែលពិបាក ដោយសារគ្រូបង្រៀនភាគច្រើនពុំសូវចង់ធ្វើការងារជាបណ្ណារក្ស ដូច្នេះបណ្ណារក្សដែលរើសបាន គឺជាគ្រូបង្រៀនដែលពុំសូវមានសុខភាពល្អ អសកម្មក្នុងការងារ និងមានចំណេះដឹងមិនសូវទូលំទូលាយ។

បណ្ណាល័យបឋមសិក្សា គឺជាចំណុចចាប់ផ្តើមយ៉ាងសំខាន់សម្រាប់បណ្តុះទម្លាប់អានដល់កុមារតាំងពីកុមារភាព ដូច្នេះទាមទារឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍបណ្ណាល័យបឋមសិក្សា ដើម្បីជំរុញការអាន បណ្តុះទម្លាប់អាន និងបង្កើតវប្បធម៌អាននៅប្រទេសកម្ពុជាយើងឡើងវិញ។ ដោយឡែកការអភិវឌ្ឍបណ្ណាល័យនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ក៏មិនអាចមើលរំលងបានដែរ ដែលត្រូវបន្តជំរុញឱ្យសិស្សមានទម្លាប់ក្នុងការអាន ការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីដំណោះស្រាយផ្សេងៗ ដើម្បីគាំទ្រដល់ការរៀនសូត្រឱ្យកាន់តែមានគុណភាពល្អប្រសើរឡើង។

សរុបសេចក្តីមក បន្ទាប់ពីបានស្វែងយល់អំពីស្ថានភាពទូទៅនៃបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជារួចមក បញ្ជាក់ឱ្យឃើញថាបណ្ណាល័យសាលារៀនមិនទាន់មានការអភិវឌ្ឍល្អប្រសើរនៅឡើយ ដែលត្រូវទាមទារឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ក្នុងការជំរុញអភិវឌ្ឍបណ្ណាល័យសាលារៀនឱ្យមានភាពរីកចម្រើន និងនិរន្តរភាព។ លើសពីនេះទៀតការដោះស្រាយបញ្ហាចំពោះធនធានមនុស្ស (បណ្ណារក្ស ឬអ្នកគ្រប់គ្រងបណ្ណាល័យ) ត្រូវចាត់ទុកជារឿងអាទិភាព ដើម្បីឱ្យបណ្ណាល័យមានដំណើរការល្អប្រសើរ។ ចុងក្រោយដើម្បីធានាឱ្យបណ្ណាល័យមានភាពរីកចម្រើន និងរក្សាបាននូវចីរភាព ទាមទារឱ្យមានអង្គភាពមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់ក្នុងការគ្រប់គ្រង ដឹកនាំ អនុវត្ត និងពិនិត្យតាមដាន លើការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅនៅកម្ពុជា។

## ២. អនុសាសន៍

ការអភិវឌ្ឍបណ្ណាល័យសាលារៀនចំណេះទូទៅគឺជារឿងដែលសំខាន់មិនអាចមើលរំលងបានឡើង ដូច្នេះ ដើម្បីអាចឱ្យការនេះទទួលបានជោគជ័យ នាយកដ្ឋានពាក់ព័ន្ធ ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា ត្រូវៈ

- បង្កើតអង្គភាពមួយដែលមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ សម្រាប់រៀបចំ គ្រប់គ្រង រៀបចំផែនការ និងអនុវត្តឱ្យបានម៉ត់ចត់

- រៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្ណារក្សអាជីព ដែលមានក្របខណ្ឌជាបណ្ណារក្ស ខុសពីក្របខណ្ឌគ្រូបង្រៀន

- ជំរុញការបំប៉នបណ្ណារក្សដែលមានស្រាប់ឱ្យមានចំណេះដឹងគ្រប់គ្រាន់ផ្នែកការងារគ្រប់គ្រងបណ្ណាល័យ

- ជ្រើសរើសអ្នកគ្រប់គ្រងការងារបណ្ណាល័យ ដែលជាមនុស្សដែលមានសមត្ថភាព សកម្មការងារ មានចំណេះដឹងទូលំទូលាយ មានសុខភាពល្អ និងមានមនសិការខ្ពស់

- រៀបចំឱ្យមានកញ្ចប់ថវិកាសម្រាប់អភិវឌ្ឍបណ្ណាល័យសាលារៀនជាប្រចាំឆ្នាំ

- កសាងអគារសិក្សាបន្ថែមតាមសាលាដែលខ្វះខាតបន្ទប់សិក្សា

- ជំរុញការផ្សព្វផ្សាយ និងស្វែងរកការឧបត្ថម្ភគាំទ្រពី សហគមន៍ អង្គការ និងដៃគូអភិវឌ្ឍន៍នានា

- បំផុសចលនានានាឱ្យលោកគ្រូ អ្នកគ្រូ យល់ពីសារៈសំខាន់របស់បណ្ណាល័យ ដើម្បីឱ្យគាត់ចូលរួមជំរុញសិស្សានុសិស្សចូលប្រើប្រាស់កាន់តែច្រើនឡើង។

# គន្ថនិទ្ទេស

១. ឃ្លោក វិបុលឡា និងអ្នកដទៃ៖  ឯកសារណែនាំការងារបណ្ណាល័យសាលាមធ្យមសិក្សា ភ្នំពេញ ឆ្នាំ២០១០

២. យឹម ម៉ូរី និងអ្នកដទៃ៖ ស្តង់ដារបណ្ណាល័យបឋមសិក្សា ភ្នំពេញ ឆ្នាំ២០១១

៣. យឹម មូរី និងអ្នកដទៃ៖ ស្តង់ដារបណ្ណាល័យមធ្យមសិក្សា ភ្នំពេញ ឆ្នាំ២០១៤

៤. អ៊ឹម ម៉ាច៖ កិច្ចការបណ្ណាល័យសម្រាប់សាលាបឋមនិងមធ្យមសិក្សា ភ្នំពេញ ឆ្នាំ២០១៣

៥. អាំង ជូបុះ ណែនាំការងារបណ្ណារក្ស ភ្នំពេញ ឆ្នាំ២០០៦